# ក

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៦-៥-២០០០ -ព្រះរាជក្រឹត្យ នស/រកត/០៥០០/០៩៣ តែងតាំងលោក ម៉ុន គឹមស៊ាន ជាឧកញ៉ា ៨៩៧

១៦-៥-២០០០ -ព្រះរាជក្រឹត្យ នស/រកត/០៥០០/០៩៤ តែងតាំងលោកឧត្តម ឈាំ ខុំ ជាទីប្រឹក្សាលោកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី ៨៩៧

១៦-៥-២០០០ -ព្រះរាជក្រឹត្យ នស/រកត/០៥០០/០៩៥ តែងតាំងលោកឧត្តម ម៉ែន ស៊ិន ជាទីប្រឹក្សាលោកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី ៨៩៨

១៩-៥-២០០០ -ព្រះរាជក្រឹត្យ នស/រកត/០៥០០/០៩៦ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល ក្រសួងមហាផ្ទៃ ៨៩៩

១៩-៥-២០០០ -ព្រះរាជក្រឹត្យ នស/រកត/០៥០០/០៩៧ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌអនុមន្ត្រីរាជការក្រសួងមហាផ្ទៃ ៩០៥

២០-៥-២០០០ -ព្រះរាជក្រឹត្យ នស/រកត/០៥០០/០៩៨ បញ្ចប់អាណត្តិបច្ចុប្បន្នជាទីប្រឹក្សាផ្ទាល់របស់ព្រះអង្គម្ចាស់អនុប្រធានទី១ នៃព្រឹទ្ធសភា ៩១១

២០-៥-២០០០ -ព្រះរាជក្រឹត្យ នស/រកត/០៥០០/០៩៩ តម្លើងឋានៈស្មើរដ្ឋលេខាធិការ ជូនលោកឧត្តម នុជ ស៊ីនិត ជាទីប្រឹក្សាផ្ទាល់របស់ព្រះអង្គម្ចាស់អនុប្រធានទី១ ព្រឹទ្ធសភា ៩១២

២២-៥-២០០០ -ព្រះរាជក្រឹត្យ នស/រកត/០៥០០/១០០ បន្តឋានៈអោយទទួលរងសោធនជូនលោក ទេពពិត ៩១៣

២៥-៥-២០០០ -ព្រះរាជក្រឹត្យ នស/រកត/០៥០០/១០២ តែងតាំងលោកឧត្តម ស៊ឹម សារ៉ាក់ ជាអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ៩១៦
លោកឧត្តម ហង្ស សុន ជាអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ៩១៧

៣១-៥-២០០០ -ព្រះរាជក្រឹត្យ នស/រកត/០៥០០/១០៣ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល ៩១៧

២

# II-រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ


១៨-៥-២០០០ -អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំកម្មវិធីជាតិ នៃសកម្មភាពអភិវឌ្ឍន៍កម្ពុជា ៩២៣

២៣-៥-២០០០ -អនុក្រឹត្យលេខ ២៨ អនក្រ.បក ស្តីពីការបង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជា ៩២៦

២៣-៥-២០០០ -អនុក្រឹត្យលេខ ២៩ អនក្រ.បក ស្តីពីការបង្វែរឥណទាន ៩២៨

៣០-៥-២០០០ -អនុក្រឹត្យលេខ ៣០ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ៩៣០

១៦-៥-២០០០ -អនុក្រឹត្យលេខ ១៧៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៩៣៦

១៦-៥-២០០០ -អនុក្រឹត្យលេខ ១៧៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៩៣៦

១៦ ៥-២០០០ -អនុក្រឹត្យលេខ ១៧៨ អនក្រ.តត ស្តីពីការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌរដ្ឋបាលស៊ីវិល នៃក្រសួងមហាផ្ទៃ ៩៣៧

១៨-៥-២០០០ -អនុក្រឹត្យលេខ ១៧៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៩៣៨

២៣-៥-២០០០ -អនុក្រឹត្យលេខ ១៨០ អនក្រ.តត ស្តីពីការតែងតាំងអភិបាលរងខេត្ត ក្រុង ៩៣៩

២៣-៥-២០០០ -អនុក្រឹត្យលេខ ១៨១ អនក្រ.តត ស្តីពីការផ្លាស់ប្តូរភារកិច្ចមន្ត្រីរាជការ ៩៤០

៩-៥-២០០០ -អនុក្រឹត្យលេខ ១៨២ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៩៤១

៣០-៥-២០០០ -អនុក្រឹត្យលេខ ១៨៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៩៤២

៣០-៥-២០០០ -អនុក្រឹត្យលេខ ១៨៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៩៤៣

៣០-៥-២០០០ -អនុក្រឹត្យលេខ ១៨៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៩៤៤

៣០-៥-២០០០ -អនុក្រឹត្យលេខ ១៨៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៩៤៥

៣០-៥-២០០០ -អនុក្រឹត្យលេខ ១៨៧ អនក្រ.តត ស្តីពីការតែងតាំងផ្លាស់ប្តូរមុខងារ និងតម្លើងឋានន្តរស័ក្តិនាយទាហាន ៩៤៦

៣១-៥-២០០០ -អនុក្រឹត្យលេខ ១៨៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៩៤៨

៣១-៥-២០០០ -អនុក្រឹត្យលេខ ១៨៩ អនក្រ.តត ស្តីពីការបំពាក់ឋានន្តរស័ក្តិនាយនគរបាលជាតិ ៩៤៩

៣១-៥-២០០០ -អនុក្រឹត្យលេខ ១៩០ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៩៥០

៣១-៥-២០០០ -អនុក្រឹត្យលេខ ១៩១ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៩៥១

៣១-៥-២០០០ -អនុក្រឹត្យលេខ ១៩២ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៩៥៣

៣១-៥-២០០០ -អនុក្រឹត្យលេខ ១៩៣ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៩៥៥

៣១-៥-២០០០ -អនុក្រឹត្យលេខ ១៩៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៩៥៦

## ២-សេចក្តីសំរេច

១៩-៥-២០០០ -សេចក្តីសំរេចលេខ ៣០ សសរ ស្តីពីការបង្កើតគណៈកម្មការទទួលរៀបចំកិច្ច ប្រជុំថ្នាក់ខ្ពស់មន្ត្រីកសិកម្ម និង ព្រៃឈើអាស៊ាន ៩៥៧

១៩-៥-២០០០ -សេចក្តីសំរេចលេខ ៣១ សសរ ស្តីពីការបង្កើតគណៈកម្មការចំរុះកម្ពុជា ឥណ្ឌា ៩៥៩

១៩-៥-២០០០ -សេចក្តីសំរេចលេខ ៣២ សសរ ស្តីពីការបង្កើតគណៈកម្មាធិការ ដឹកនាំការងារ គំរោងជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ីសំរាប់អភិវឌ្ឍន៍ប្រព័ន្ធស្ថិតិ ជាតិកម្ពុជា ( ២០០០ ២០០៣ ) ៩៦១

២៣-៥-២០០០ -សេចក្តីសំរេចលេខ ៣៣ សសរ ស្តីពីការផ្ទេរសិទ្ធិ នៃរាជរដ្ឋាភិបាល ៩៦៣

៣១-៥-២០០០ -សេចក្តីសំរេចលេខ ៣៤ សសរ ស្តីពីការផ្ទេរសិទ្ធិ នៃរាជរដ្ឋាភិបាល ៩៦៤

៣១-៥-២០០០ -សេចក្តីសំរេចលេខ ៣៥ សសរ ស្តីពីការប្រគល់ភារកិច្ចជូនទីប្រឹក្សា ៩៦៥

# III- ការងារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

### ប្រកាស

២៣-៥-២០០០ -ប្រកាសលេខ ១៩៤/០០ ពម.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ៩៦៦

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ១-ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០៥០០/០៩៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោក ម៉ិត គឹមស៊ាន

ជា

ឧកញ៉ា

ធ្វើនៅព្រះបរមរាជវាំងភ្នំពេញ, ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

### ព្រះរាជក្រឹត្យ នស/រកត/០៥០០/០៩៤

យើង

ព្រះបាទសម្តេចព្រះនរោត្តមសីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

****

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ .**_ តែងតាំងលោកឧត្តម ឈាំ ឆុំ ជាទីប្រឹក្សាឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើនឹង អនុរដ្ឋលេខាធិការ ។

**មាត្រា ២ .**_ បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .**_ នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តអោយបានសំរេចព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ .**_ ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

**ព្រះរាជក្រឹត្យ នស/រកត/០៥០០/០៩៥**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

****

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានទ្រង់ឃើញព្រះរាជក្រមលេខ នស/រកម/០៧៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់បានសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ ._ តែងតាំងឯកឧត្តម ម៉ែន អ៊ិន ជាទីប្រឹក្សាឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី អាននាំងសេរីអង រដ្ឋលេខាធិការ និងមានឋានន្តរសក្តិជាអនុរដ្ឋលេខាធិការ ។

មាត្រា ២ ._ បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ ._ នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ ._ ព្រះរាជក្រឹត្យនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០០០

ព្រះហស្ថលេខា

នរោត្តម សីហនុ

★★★

# ព្រះរាជក្រឹត្យ នស/រកត/០៥០០/០៩៦

# ស្តីពី លក្ខន្តិកៈដោយឡែក

# នៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល

# ក្រសួងមហាផ្ទៃ

****

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

****

- បានទ្រង់ឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃ១២ ខែតុលា ឆ្នាំ២០០០

## ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

ត្រូវបានបង្កើតក្របខ័ណ្ឌលេខាធិការរដ្ឋបាលរបស់ក្រសួងមហាផ្ទៃ ដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ ខ ដូចបានចែងក្នុងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

**មាត្រា ២ .-**

មន្ត្រីរាជការនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាលនេះ ត្រូវស្ថិតនៅក្រោមឱវាទក្រសួងមហាផ្ទៃ ។

**មាត្រា ៣ .-**

មន្ត្រីរាជការនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ មានមុខងារក្នុងលេខាធិការដ្ឋាន និងមុខងារប្រតិបត្តិនៅអង្គភាពរដ្ឋបាលកណ្តាល របស់ក្រសួងមហាផ្ទៃ និង តាមខេត្ត ក្រុង ។

## ជំពូកទី ២

## ឋានន្តរស័ក្តិ ថ្នាក់ និង មុខតំណែងក្របខ័ណ្ឌ

**មាត្រា ៤ .-**

ក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃមាន ៣ ឋានន្តរស័ក្តិ :

-នាយលេខាធិការរដ្ឋបាល : មាន ០៦ ថ្នាក់

-លេខាធិការរដ្ឋបាលជើងខ្សែ : មាន ១០ ថ្នាក់

-លេខាធិការរដ្ឋបាល : មាន ១៤ ថ្នាក់ ។

**មាត្រា ៥ .-**

មន្ត្រីរាជការនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាលរបស់ក្រសួងមហាផ្ទៃនេះ មានមុខវិជ្ជាដែលអាចបំពេញមុខតំណែងជា :

-អនុប្រធានការិយាល័យ នៅតាមសាលាក្រុង ខ័ណ្ឌ

-មេឃុំ សង្កាត់

និងមុខតំណែងផ្សេងទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួងមហាផ្ទៃ ។

## ជំពូកទី ៣
## ការជ្រើសរើស និង ការបណ្តុះបណ្តាលដំបូង

មាត្រា ៦ .-

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ ត្រូវធ្វើតាមរបៀបការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ឬ និងក្នុងចំណោមសិស្ស និស្សិត ។ ចំនួននៃតំណែងដែលត្រូវផ្តល់ក្នុងការប្រឡងប្រជែងសំរាប់មន្ត្រីរាជការ និង សិស្ស និស្សិត ត្រូវកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងមហាផ្ទៃ ។

មាត្រា ៧ .-

ការប្រឡងប្រជែងក្នុងចំណោមសិស្ស និស្សិត ត្រូវធ្វើចំពោះបេក្ខជនដែលមានសញ្ញាប័ត្រយ៉ាងទាបបំផុតសមមូលនឹងមធ្យមសិក្សាប័ត្រភាគទី ២ និង មានអាយុយ៉ាងច្រើន ២៥ ឆ្នាំ គិតរហូតដល់ថ្ងៃប្រឡង ។ អាយុនេះអាចរំកិលពី ២៥ ឆ្នាំឡើងដល់ ៣០ ឆ្នាំ ស្របតាមមាត្រា ១១ នៃលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

ការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវធ្វើចំពោះមន្ត្រីរាជការដែលស្ថិតយ៉ាងទាបបំផុតក្នុងថ្នាក់លេខ ១១ របស់ក្របខ័ណ្ឌប្រភេទ ឃ និង មានអាយុយ៉ាងច្រើន ៥០ ឆ្នាំ ។

ចំពោះមន្ត្រីរាជការរបស់ក្រសួងមហាផ្ទៃ ដែលមានសញ្ញាប័ត្រយ៉ាងទាបបំផុតសមមូលនឹងមធ្យមសិក្សាប័ត្រភាគទី ២ អាចប្រឡងចូលក្នុងក្របខ័ណ្ឌនេះបាន ដោយពុំគិតពីលក្ខខ័ណ្ឌ ឋានន្តរស័ក្តិ និង ប្រភេទក្របខ័ណ្ឌឡើយ ហើយមានអាយុយ៉ាងច្រើនបំផុត ៥០ ឆ្នាំ ។

មាត្រា ៨ .-

បេក្ខជនដែលត្រូវបានជ្រើសរើស តាមរបៀបការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ និងក្នុងចំណោមសិស្ស និស្សិត មានឋានៈជាសិស្សមន្ត្រីលេខាធិការរដ្ឋបាល ហើយការបណ្តុះបណ្តាលដំបូងត្រូវរៀបចំឡើងដោយក្រសួងមហាផ្ទៃ ។

## ជំពូកទី ៤
## កម្មសិក្សា និង ការតាំងស៊ប់

មាត្រា ៩ .-

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង សិស្សមន្ត្រីលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ ត្រូវបានចាត់អោយទៅបំពេញការងារ តាមអង្គភាពនានា ក្រោមឱវាទក្រសួងមហាផ្ទៃ ហើយត្រូវបានតែងតាំងជាមន្ត្រីលេខាធិការរដ្ឋបាលកម្មសិក្សាដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

មន្ត្រីកម្មសិក្សាទាំងនេះ ត្រូវឆ្លងកាត់កម្មសិក្សាមួយ ដែលមានរយៈពេលដូចខាងក្រោម ៖

១-១២ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីសិស្ស និស្សិត ។

២-០៦ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ហើយដែលពីមុន នេះពុំស្ថិតក្នុងក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ។

ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ហើយដែលពីមុននេះស្ថិតក្នុងក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលរបស់ក្រសួងមហាផ្ទៃ ពុំចាំបាច់ឆ្លងកាត់កម្មសិក្សាសាកល្បងឡើយ ។

ក្រោយពេលធ្វើកម្មសិក្សាសាកល្បង មន្ត្រីដែលតែងក្នុងចំណុចទី១ និងទី២ខាងលើត្រូវបានតាំងស៊ប់ក្នុងឋានន្តរសក្តិលេខាធិការរដ្ឋបាល ។ ក្នុងករណីចាំបាច់អាចត្រូវបានអនុញ្ញាតអោយធ្វើកម្មសិក្សាបន្ថែមដែលមានរយៈពេលអតិបរមាត្រឹម ១២ ខែចំពោះមន្ត្រីដែលមានតែងក្នុងចំណុចទី១ និង០៦ខែចំពោះមន្ត្រីដែលមានតែងក្នុងចំណុចទី២ ។ មន្ត្រីដែលពុំបានទទួលជោគជ័យក្នុងការបំពេញកម្មសិក្សាបន្ថែមនេះត្រូវលុបឈ្មោះចោលប្រសិនបើចេញមកពីសិស្ស និស្សិត ឬអាចបញ្ជូនទៅក្របខ័ណ្ឌដើមវិញ ប្រសិនបើចេញមកពីមន្ត្រីរាជការ ដោយពិតបញ្ញាត្តិរាប់អតីតភាពការងារ ។ ករណីខាងលើទាំងនេះ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ តាមសំណើរបស់អង្គភាពសាម៉ីដោយភ្ជាប់នូវមូលហេតុ ធ្វើឡើងរយៈពេលយ៉ាងយូរ ០៣ ខែ ក្រោយការបញ្ចប់កម្មសិក្សា ។

មន្ត្រីលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ ដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវបញ្ចូលទៅក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សរ៍ស្មើឬលើសបន្ទាប់ពីសន្ទស្សន៍ចាស់របស់សាមីខ្លួន ។

មន្ត្រីលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ ដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមសិស្ស និស្សិត ត្រូវបញ្ចូលទៅក្នុងថ្នាក់លេខ ១៥ នៃឋានន្តរសក្តិលេខាធិការរដ្ឋបាល ។

ការតែងតាំងស៊ប់ក្នុងឋានន្តរសក្តិលេខាធិការរដ្ឋបាល នៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

## ជំពូកទី ៥

## ការតែងតាំង

**មាត្រា ១០ .-**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃរួចហើយ មន្ត្រីលេខាធិការរដ្ឋបាលទាំងនេះ អាចត្រូវបានតែងតាំង ក្នុងមុខតំណែងទំនេរណាមួយដូចមានចែងក្នុងមាត្រា ៥ ខាងលើ ស្របតាមឋានន្តរសក្តិរបស់ខ្លួន ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ តាមបែបបទដូចបានកំណត់ក្នុងមាត្រា ២៩ នៃព្រះរាជក្រមលេខ ០២/នស/៩៥ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ៦

## ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរស័ក្តិ

មាត្រា ១១ .-

មន្ត្រីនៃក្របខ័ណ្ឌមេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ ត្រូវបានតម្លើងថ្នាក់ទៅតាមលក្ខខ័ណ្ឌដូចបាន ចែងក្នុងមាត្រា ២០ និង មាត្រាបន្តបន្ទាប់នៃលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

លក្ខណៈសម្បត្តិជាមូលដ្ឋានដែលត្រូវពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោម :

-គោរពវិន័យការងារបានត្រឹមត្រូវ

-មានស្មារតីទទួលខុសត្រូវ

-សំរេចបាននូវភារកិច្ចដែលប្រគល់អោយ

-មានសីលធម៌ល្អ ។

ការឡើងថ្នាក់នៃមន្ត្រីរាជការក្នុងក្របខ័ណ្ឌនេះត្រូវធ្វើក្នុងសមាមាត្រ ៣ ភាគ៤តាមវេនជ្រើសរើស និង ១ភាគ ៤តាមវេនអតីតភាព ។

មាត្រា ១២ .-

គោលការណ៍នៃការតម្លើងឋានន្តរស័ក្តិ ត្រូវតម្លើងទៅក្នុងថ្នាក់ដំបូងនៃឋានន្តរស័ក្តិខ្ពស់បន្ទាប់ ឬ ក្នុងករណីចាំបាច់ ត្រូវតម្លើងទៅក្នុងថ្នាក់ដែលត្រូវជាមួយសន្ទស្សន៍ខ្ពស់បន្ទាប់ពីសន្ទស្សន៍ចាស់របស់ មន្ត្រីសាមី ។

ការតម្លើងឋានន្តរស័ក្តិ ត្រូវអនុវត្តអោយបានស្របជាមួយចំនួនតំណែងដែលទំនេរ នៅក្នុងឋានន្តរស័ក្តិនោះ ហើយត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬតាមរយៈការប្រឡងប្រជែងដោយ រក្សាគោលការណ៍ភាគរយ :

-៥ ភាគរយ ចំពោះឋានន្តរស័ក្តិនាយកមេខាធិការរដ្ឋបាល

-២៥ ភាគរយ ចំពោះឋានន្តរស័ក្តិមេខាធិការរដ្ឋបាលដើមខ្សែ

-៧០ ភាគរយ ចំពោះឋានន្តរស័ក្តិមេខាធិការរដ្ឋបាល ។

ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរស័ក្តិ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា ១៣ ._**

អាចតម្លើងទៅក្នុងឋានន្តរសក្តិលេខាធិការរដ្ឋបាលដើមខ្សែ គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋានន្តរសក្តិលេខាធិការរដ្ឋបាល ។

អាចតម្លើងទៅក្នុងឋានន្តរសក្តិនាយលេខាធិការរដ្ឋបាល គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ៧ នៃឋានន្តរសក្តិលេខាធិការរដ្ឋបាលដើមខ្សែ ។

**មាត្រា ១៤ ._**

សន្ទស្សន៍សំរាប់ថ្នាក់ ក្នុងឋានន្តរសក្តិនីមួយៗ នៃក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ និងតម្លៃឯកត្តានៃសន្ទស្សន៍ព្រមទាំងរបបពេលការផ្សេងៗ ទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

## ជំពូកទី ៧

## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៥ ._**

មន្ត្រីនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ ដែលមានសញ្ញាប័ត្រមធ្យមសិក្សាប័ត្រភាគទី ២ បូកពីរឆ្នាំសិក្សាក្នុងគ្រឹស្ថានឧត្តមសិក្សាដោយមានសញ្ញាប័ត្រ ត្រូវបានតម្លើងថ្នាក់មួយថ្នាក់ជាស្វ័យប្រវត្តិ ។

**មាត្រា ១៦ ._**

មន្ត្រីនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ ត្រូវដាក់អោយចូលនិវត្តន៍នៅពេលដល់អាយុ ៥៥ ឆ្នាំ ។ ចំពោះការដាក់អោយចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

## ជំពូកទី ៨

## អន្តរប្បញ្ញត្តិ

**មាត្រា ១៧ ._**

ចំនួនដំបូងនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ ត្រូវកសាងចេញពីសមាហរណកម្មនៃមន្ត្រីរាជការទាំងឡាយ ដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និង មុខងារពិតប្រាកដរបស់ក្របខ័ណ្ឌ ក្នុងរដ្ឋបាលកណ្តាលរបស់ក្រសួងមហាផ្ទៃ និង តាមខេត្ត ក្រុង ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ១៨ ._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៩ ._**

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ២០ ._ ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ                    រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០០

ព្រះមហាក្សត្រ សូមឡាយព្រះហស្ថលេខា                    ព្រះហស្ថលេខា

នាយករដ្ឋមន្ត្រី                    នរោត្តម សីហនុ

ហត្ថលេខា

ហ៊ុន សែន

បានយកសេចក្តីជំរាបជូនសម្តេច

នាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា

ស ខេង    យូ ហុកគ្រី

★★★

# ព្រះរាជក្រឹត្យ នស/រកត/០៥០០/០៩៧

## ស្តីពី

## លក្ខន្តិកៈដោយឡែក

## នៃគ្រូបង្ហាត់អនុរក្សពន្ធនាគារ

## ក្រសួងមហាផ្ទៃ

***

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

****

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានទ្រង់ឡាយព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ឡាយ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់ឡាយព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី១២ ខែតុលា ឆ្នាំ២០០០

**ត្រាស់បង្គាប់**

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ ._**

ត្រូវបានបង្កើតក្របខ័ណ្ឌអនុរក្សពន្ធនាគារនៃក្រសួងមហាផ្ទៃ ដែលត្រូវបានចាត់ទុកជាក្របខ័ណ្ឌ ដូចបានចែងក្នុងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

**មាត្រា ២ ._**

មន្ត្រីរាជការនៃក្របខ័ណ្ឌអនុរក្សពន្ធនាគារនេះ ត្រូវស្ថិតនៅក្រោមឱវាទក្រសួងមហាផ្ទៃ ។

**មាត្រា ៣ ._**

មន្ត្រីរាជការនៃក្របខ័ណ្ឌអនុរក្សពន្ធនាគារមានភារកិច្ច ជាទូទៅក្នុងមុខងារគ្រប់គ្រង អប់រំអ្នកទោស រាល់ការងាររដ្ឋបាល និង កិច្ចប្រតិបត្តិការក្នុងពន្ធនាគារកណ្តាល និង ពន្ធនាគារតាមខេត្ត ក្រុង ។

## ជំពូកទី ២

## ឋានន្តរសក្តិ ថ្នាក់ និង មុខតំណែងក្របខ័ណ្ឌ

**មាត្រា ៤ ._**

ក្របខ័ណ្ឌអនុរក្សពន្ធនាគារមាន ៣ ឋានន្តរសក្តិ :

-នាយអនុរក្ស : មាន ០៦ ថ្នាក់

-អនុរក្សជើងខ្សែ : មាន ១០ ថ្នាក់

-អនុរក្ស : មាន ១៤ ថ្នាក់ ។

**មាត្រា ៥ ._**

-មន្ត្រីរាជការក្នុងឋានន្តរសក្តិនាយអនុរក្ស មានឧបនិស្ស័យសំរាប់កាន់ មុខតំណែងជា :

-នាយផ្នែករដ្ឋបាល និងកិច្ចប្រតិបត្តិការប្រចាំថ្ងៃក្នុងពន្ធនាគារ និងមុខតំណែងដទៃទៀត ដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ពន្ធនាគារ ។

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិ អនុរក្សដើមខ្សែ មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងជា :

-នាយរងផ្នែករដ្ឋបាល និងការកិច្ចប្រតិបត្តិក្នុងពន្ធនាគារ

និងមុខតំណែងដទៃទៀតដែលមានថ្នាក់ ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធ របស់ពន្ធនាគារ ។

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិអនុរក្ស មានឧបនិស្ស័យកាន់មុខតំណែងជា :

-អ្នកគ្រប់គ្រង អ្នកទោសក្នុងពន្ធនាគារ ។

## ជំពូកទី ៣

## ការជ្រើសរើស និង ការបណ្តុះបណ្តាលដំបូង

**មាត្រា ៦ .-**

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌអនុរក្សពន្ធនាគារ ត្រូវធ្វើតាមរយៈការប្រឡងប្រជែងក្នុងចំណោម មន្ត្រីរាជការ ឬ និងក្នុងចំណោមសិស្ស និស្សិត ។ ចំនួននៃតំណែងដែលត្រូវផ្តល់ក្នុងការប្រឡងប្រជែង សម្រាប់មន្ត្រីរាជការ និង សិស្ស និស្សិត ត្រូវកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា ៧ .-**

ការប្រឡងប្រជែងក្នុងចំណោមសិស្ស និស្សិត ត្រូវធ្វើចំពោះបេក្ខជនដែលមានសញ្ញាប័ត្រយ៉ាងទាបបំផុត សមមូលនឹងមធ្យមសិក្សាប័ត្រភាគទី ២ និង មានអាយុយ៉ាងច្រើន ២៥ ឆ្នាំ គិតរហូតដល់ថ្ងៃប្រឡង ។ អាយុ នេះអាចកើនពី ២៥ ឆ្នាំឡើងដល់ ៣០ ឆ្នាំ ស្របតាមមាត្រា ១១ នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

ការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវធ្វើចំពោះមន្ត្រីរាជការដែលស្ថិតយ៉ាងទាបបំផុតក្នុងថ្នាក់ លេខ ១១ របស់ក្របខ័ណ្ឌប្រភេទ ឃ និង មានអាយុយ៉ាងច្រើន ៤០ ឆ្នាំ ។

ចំពោះមន្ត្រីរាជការរបស់ក្រសួងមហាផ្ទៃ ដែលមានសញ្ញាប័ត្រយ៉ាងទាបបំផុតសមមូលនិងមធ្យមសិក្សាប័ត្រភាគទី ២ អាចប្រឡងចូលក្នុងក្របខ័ណ្ឌនេះបាន ដោយពុំគិតពីប័ក្ខខ័ណ្ឌ ឋានន្តរស័ក្តិ និង ប្រភេទក្របខ័ណ្ឌឡើយ ហើយមានអាយុយ៉ាងច្រើនបំផុត ៤០ ឆ្នាំ ។

**មាត្រា ៨ .-**

បេក្ខជនដែលត្រូវបានជ្រើសរើស តាមរយៈការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ និងក្នុងចំណោម សិស្ស និស្សិត មានឋានៈជាសិស្សមន្ត្រីអនុរក្សពន្ធនាគារ ហើយការបណ្តុះបណ្តាលដំបូងត្រូវរៀបចំឡើង ដោយក្រសួងមហាផ្ទៃ ។

## ជំពូកទី ៤
## កម្មសិក្សា និង ការតាំងស៊ប់

**មាត្រា ៩ ._**

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង សិស្សមន្ត្រីអនុរក្សពន្ធនាគារ ត្រូវបានចាត់អោយ ទៅបំពេញការងារតាមពន្ធនាគារនានា ក្រោមឱវាទក្រសួងមហាផ្ទៃ ហើយត្រូវបានតែងតាំងជាមន្ត្រីអនុរក្សពន្ធនាគារ កម្មសិក្សា ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

មន្ត្រីកម្មសិក្សាទាំងនេះ ត្រូវឆ្លងកាត់កម្មសិក្សាសាកល្បងមួយ ដែលមានរយៈពេលដូចខាងក្រោម ៖

១-១២ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីសិស្ស និស្សិត ។

២-០៦ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ហើយដែលពីមុននេះពុំស្ថិតក្នុងក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ។

ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ហើយដែលពីមុននេះស្ថិតក្នុងក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលរបស់ក្រសួងមហាផ្ទៃ ពុំចាំបាច់ឆ្លងកាត់កម្មសិក្សាសាកល្បងឡើយ ។

ក្រោយពេលធ្វើកម្មសិក្សាសាកល្បង មន្ត្រីដែលចែងក្នុងចំណុចទី១ និងទី២ខាងលើត្រូវបានតាំងស៊ប់ក្នុងឋានន្តរស័ក្តិអនុរក្ស ។ ក្នុងករណីចាំបាច់ អាចត្រូវបានអនុញ្ញាតអោយធ្វើកម្មសិក្សាបន្ថែមដែលមានរយៈពេលអតិបរមាត្រឹម ១២ ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី១ និង០៦ខែចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី២ ។ មន្ត្រីដែលពុំបានទទួលជោគជ័យក្នុងការបំពេញកម្មសិក្សាបន្ថែមនេះ ត្រូវលុបឈ្មោះចោល ប្រសិនបើចេញមកពីសិស្ស និស្សិត ឬមួយបញ្ជូនទៅក្របខ័ណ្ឌដើមវិញ ប្រសិនបើចេញមកពីមន្ត្រីរាជការ ដោយគិតបញ្ចូលសំរាប់អតីតភាពការងារ ។ ករណីខាងលើទាំងនេះ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ តាមសំណើរបស់អង្គភាពសាមីដោយបញ្ជាក់នូវមូលហេតុ ធ្វើឡើងរយៈពេលយ៉ាងយូរ ០៣ ខែក្រោយការបញ្ចប់កម្មសិក្សាសាកល្បង ។

មន្ត្រីអនុរក្សពន្ធនាគារ ដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវបញ្ចូលទៅក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់សាមីខ្លួន ។

មន្ត្រីអនុរក្សពន្ធនាគារ ដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមសិស្ស និស្សិតត្រូវបញ្ចូលទៅក្នុងថ្នាក់លេខ ១៥ នៃឋានន្តរស័ក្តិអនុរក្ស ។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិអនុរក្ស នៃក្របខ័ណ្ឌអនុរក្សពន្ធនាគារ ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

## ជំពូកទី ៥
## ការតែងតាំង

មាត្រា ១០ ._

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌអនុរក្សពន្ធនាគាររួចហើយ មន្ត្រីអនុរក្សពន្ធនាគារទាំងនេះ អាចត្រូវបានតែងតាំង ក្នុងមុខតំណែងទំនេរណាមួយដូចមានចែងក្នុងមាត្រា ៥ ខាងលើស្របតាមឋានន្តរសក្តិរបស់ខ្លួន ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ តាមបែបបទដូចបានកំណត់ក្នុងមាត្រា ២៨ នៃព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ៦
## ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរសក្តិ

មាត្រា ១១ ._

មន្ត្រីនៃក្របខ័ណ្ឌអនុរក្សពន្ធនាគារ ត្រូវបានតម្លើងថ្នាក់ទៅតាមលក្ខខ័ណ្ឌដូចបាន ចែងក្នុងមាត្រា ២០ និង មាត្រាបន្តបន្ទាប់នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

លក្ខណៈសម្បត្តិជាមូលដ្ឋានដែលត្រូវពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោម ៖

-គោរពវិន័យការងារបានត្រឹមត្រូវ

-មានស្មារតីទទួលខុសត្រូវ

-សំរេចបាននូវភារកិច្ចដែលប្រគល់អោយ

-មានសីលធម៌ល្អ ។

ការឡើងថ្នាក់នៃអ្នករាជការក្នុងក្របខ័ណ្ឌនេះត្រូវគិតក្នុងសមាមាត្រ ៣ ភាគ៤តាមវេនជ្រើសរើស និង ១ភាគ ៤តាមវេនអតីតភាព ។

មាត្រា ១២ ._

គោលការណ៍នៃការតម្លើងឋានន្តរសក្តិ ត្រូវតម្លើងទៅក្នុងថ្នាក់ដំបូងនៃឋានន្តរសក្តិខ្ពស់លើបន្ទាប់ ឬក្នុងករណីចាំបាច់ ត្រូវតម្លើងទៅក្នុងថ្នាក់ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី ។

ការតម្លើងឋានន្តរសក្តិ ត្រូវអនុវត្តអោយបានស្របជាមួយចំនួនតំណែងដែលទំនេរ នៅក្នុងឋានន្តរសក្តិនោះ ហើយត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរសក្តិ ឬតាមរយៈការប្រឡងប្រជែង ។

ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរសក្តិ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

មាត្រា ១៣ ._

អាចតម្លើងទៅក្នុងឋានន្តរសក្តិអនុរក្សដើមខ្សែ គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់ លេខ ១១ នៃឋានន្តរសក្តិអនុរក្ស ។

អាចតម្លើងទៅក្នុងឋានន្តរសក្តិនាយអនុរក្ស គឺមន្ត្រីទាំងឡាយណាដែលបានឡើងដល់ថ្នាក់លេខ ៧ នៃឋានន្តរសក្តិអនុរក្សដើមខ្សែ ។

ការតម្លើងទៅក្នុងឋានន្តរសក្តិមួយខ្ពស់ជាង អាចធ្វើទៅបានលុះត្រាតែមន្ត្រីមានគុណសម្បត្តិគ្រប់គ្រាន់កាន់មុខតំណែងត្រូវតាមឋានន្តរសក្តិថ្មីនោះ ដូចបានកំណត់ក្នុងមាត្រា ៥ នៃលក្ខន្តិកៈដោយឡែកនេះ ។

**មាត្រា ១៤ .-**

សន្ទស្សន៍សំរាប់ថ្នាក់ ក្នុងឋានន្តរសក្តិនីមួយៗ នៃក្របខ័ណ្ឌអនុរក្សពន្ធនាគារ និង តម្លៃនៃពិន្ទុសន្ទស្សន៍ព្រមទាំងរបបឧបត្ថម្ភផ្សេងៗទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

**ជំពូកទី ៧**

**បទប្បញ្ញត្តិដោយឡែក**

**មាត្រា ១៥ .-**

មន្ត្រីនៃក្របខ័ណ្ឌ អនុរក្សពន្ធនាគារ ដែលមានសញ្ញាប័ត្រមធ្យមសិក្សាប័ត្រទី២ ឬកំរិតវប្បធម៌ស្មើ ហើយបានបញ្ចប់ការសិក្សាក្នុងគ្រឹះស្ថានឧត្តមសិក្សាដោយមានសញ្ញាប័ត្រ ត្រូវបានតម្លើងថ្នាក់មួយថ្នាក់តាមលំដាប់អាទិភាព ។

**មាត្រា ១៦ .-**

មន្ត្រីនៃក្របខ័ណ្ឌ អនុរក្សពន្ធនាគារ ត្រូវដាក់ឲ្យចូលនិវត្តន៍នៅពេលដល់អាយុ ៥៥ ឆ្នាំ ។ ចំពោះការដាក់ឲ្យចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា ១៧ .-**

ឯកសណ្ឋាន និង សញ្ញាសក្តិសំរាប់មន្ត្រីអនុរក្សពន្ធនាគារ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**ជំពូកទី ៨**

**អន្តរប្បញ្ញត្តិ**

**មាត្រា ១៨ .-**

ចំនួនដំបូងនៃក្របខ័ណ្ឌអនុរក្សពន្ធនាគារ ត្រូវកកកើតចេញពីសមាហរណកម្មនៃមន្ត្រីរាជការទាំងឡាយ ដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌនៅពន្ធនាគារ កណ្តាល និងតាមខេត្ត ក្រុង ។

**ជំពូកទី ៩**

**អវសានប្បញ្ញត្តិ**

**មាត្រា ១៩ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ២០ .-**

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ២១.- ព្រះរាជក្រឹត្យនេះមានអានុភាព ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០០

ព្រះហស្ថលេខា

នរោត្តម សីហនុ

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្ថលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានយកសេចក្ដីជំរាបជូនសម្ដេច

នាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា

ស ខេង យូ ហុកគ្រី

★★★

# ព្រះរាជក្រឹត្យ នស/រកត/០៥០០/០៩៨

**យើង**

**ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

****

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្ដីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥៩៩/១១៨ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ១៩៩៩
- យោងតាមសំណើរបស់ប្រធានព្រឹទ្ធសភា ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០០

ត្រាស់បង្គាប់

មាត្រា ១ .- ត្រូវបានបញ្ចប់អាណត្តិបុច្ចុប្បន្នជាទីប្រឹក្សាផ្ទាល់របស់ព្រះអង្គម្ចាស់អនុប្រធានទី១ នៃព្រឹទ្ធសភា ៖

១-ឯកឧត្តម តាន់ ហារីស្ទី

២-ឯកឧត្តម ស្រី សុម៉ាណូ

៣-ឯកឧត្តម ចាន់ ចំរើន

៤-ឯកឧត្តម អ៊ួន ខេង

មាត្រា ២ .- ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

## ព្រះរាជក្រឹត្យ នស/រកត/០៥០០/០៩៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

****

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥៩៩/១១៨ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ១៩៩៩
- យោងតាមសំណើរបស់ប្រធានព្រឹទ្ធសភា ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០០

ត្រាស់បង្គាប់

មាត្រា ១ ._ ត្រូវបានតំឡើងឋានៈស្មើ រដ្ឋលេខាធិការ ជូនឯកឧត្តម គុជ ស៊ីនិត ជាទីប្រឹក្សាផ្ទាល់របស់ព្រះអង្គម្ចាស់ អនុប្រធានទី១ នៃព្រឹទ្ធសភា ។

មាត្រា ២ ._ ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០០

ព្រះហស្ថលេខា

នរោត្តម សីហនុ

★★★

ព្រះរាជក្រឹត្យ នស/រកត/០៥០០/១០០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

****

បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បានទ្រង់យល់ក្រឹត្យលេខ ២៨ក្រ ចុះថ្ងៃទី ២០-៦-៨៨

ត្រាស់បង្គាប់

មាត្រា ១ ._ ត្រូវបន្ថយរយៈទទួលរងទោសចំនួន ១២ខែ ឲ្យទណ្ឌិតចំនួន ០៦ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អ ក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចរាយឈ្មោះខាងក្រោមនេះ ៖

១-ទណ្ឌិតឈ្មោះ សួន គួ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៧ ឆ្នាំ តាមអំណាចសាលក្រម លេខ ២០ ចុះថ្ងៃទី ២៦-៨-៩២ របស់តុលាការខេត្តបាត់ដំបង ។

២-ទណ្ឌិតឈ្មោះ គាត់ ចាន់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២១ ចុះថ្ងៃទី ២៩-៨-៩២ របស់តុលាការខេត្តបាត់ដំបង ។

៣-ទណ្ឌិតឈ្មោះ គាត់ ណន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣៧ ចុះថ្ងៃទី ១០-៨-៩៣ របស់តុលាការខេត្តបាត់ដំបង ។

៤-ទណ្ឌិតឈ្មោះ ស្រី សារុន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ ចុះថ្ងៃទី ០៤-៥-៩៤ របស់តុលាការខេត្តបាត់ដំបង ។

៥-ទណ្ឌិតឈ្មោះ ហួន ហាត់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ឆ្នាំ តាមអំណោចសាលក្រមលេខ ៦ ចុះថ្ងៃទី ២៤-៥-៨៩ របស់តុលាការខេត្តកំពង់ធំ ។

៦-ទណ្ឌិតឈ្មោះ ឡូម ឡោម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ អស់មួយជីវិត តាមអំណោចសាលក្រមលេខ ៦ ចុះថ្ងៃទី ២៤-៥-៨៩ របស់តុលាការខេត្ត កំពង់ធំ ។

មាត្រា ២ ._ ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៩ខែ ឲ្យទណ្ឌិតចំនួន ១១នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោម ៖

១-ទណ្ឌិតឈ្មោះ ឈឿន សុខ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ឆ្នាំ តាមអំណោចសាលក្រមលេខ ១៩ ចុះថ្ងៃទី ១៩-៥-៩៤ របស់តុលាការខេត្តបាត់ដំបង ។

២-ទណ្ឌិតឈ្មោះ នាង ទិន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ឆ្នាំ តាមអំណោចសាលក្រមលេខ ១៩ ចុះថ្ងៃទី ១៨-៦-៩៣ របស់តុលាការខេត្តបាត់ដំបង ។

៣-ទណ្ឌិតឈ្មោះ ទុំ មុំ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ឆ្នាំ តាមអំណោចសាលក្រមលេខ ៧៧ ចុះថ្ងៃទី ២៨-៣-៩៥ របស់តុលាការខេត្តបាត់ដំបង ។

៤-ទណ្ឌិតឈ្មោះ គ្រាន ឆាត់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណោចសាលក្រមលេខ ២៤ ចុះថ្ងៃទី ២១-៩-៩២ របស់តុលាការខេត្តបាត់ដំបង ។

៥-ទណ្ឌិតឈ្មោះ គឹម សារី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណោចសាលក្រមលេខ ០១ ចុះថ្ងៃទី ១៤-០១-៩៣ របស់តុលាការខេត្តបាត់ដំបង ។

៦-ទណ្ឌិតឈ្មោះ កែវ ម៉ាច់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណោចសាលក្រមលេខ ៣៥៩ ចុះថ្ងៃទី ១៣-១២-៩៥ របស់តុលាការខេត្តបាត់ដំបង ។

៧-ទណ្ឌិតឈ្មោះ នឹម សឿម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណោចសាលក្រមលេខ១៣ ចុះថ្ងៃទី ២២-០១-៩៦ របស់តុលាការខេត្តបាត់ដំបង ។

៨-ទណ្ឌិតឈ្មោះ ម៉ុន យឹន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណោចសាលក្រមលេខ ៥៤ ចុះថ្ងៃទី ២៣-០២-៩៦ របស់តុលាការខេត្តបាត់ដំបង ។

៩-ទណ្ឌិតឈ្មោះ ហម ហន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណោចសាលក្រមលេខ ១៥៣ ចុះថ្ងៃទី ០៥-៧-៩៦ របស់តុលាការខេត្តបាត់ដំបង ។

១០-ទណ្ឌិតឈ្មោះ នួន សឿក ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណោចសាលក្រមលេខ ០១ ចុះថ្ងៃទី ១៤-០១-៩៣ របស់តុលាការខេត្តបាត់ដំបង ។

១១-ទណ្ឌិតឈ្មោះ ចាន់ ខួន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ឆ្នាំ តាមអំណោចសាលក្រមលេខ ១១ ចុះថ្ងៃទី ៩-៧-៩២ របស់តុលាការខេត្ត កំពង់ធំ ។

មាត្រា ៣ ._ ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៦ខែ ឲ្យទណ្ឌិតចំនួន ១៧នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោម ៖

១-ទណ្ឌិតឈ្មោះ ឡៀក ឈាង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៩ ចុះថ្ងៃទី ២៦-៨-៩៤ របស់តុលាការខេត្តព្រៃវែង ។

២-ទណ្ឌិតឈ្មោះ សេខ ប៊ិខ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨១ ចុះថ្ងៃទី ១៨-១០-៩៤ របស់តុលាការខេត្តព្រៃវែង ។

៣-ទណ្ឌិតឈ្មោះ ហួន ម៉ុនធឿន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣១ ចុះថ្ងៃទី ១៧-៣-៩៤ របស់តុលាការខេត្តបាត់ដំបង ។

៤-ទណ្ឌិតឈ្មោះ ជួន ឧត្តី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧១ ចុះថ្ងៃទី ២៣-៥-៩៤ របស់តុលាការខេត្តបាត់ដំបង ។

៥-ទណ្ឌិតឈ្មោះ ទ៉ាន់ សារេត ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០៣ ចុះថ្ងៃទី ២៧-៧-៩៤ របស់តុលាការខេត្តបាត់ដំបង ។

៦-ទណ្ឌិតឈ្មោះ ឡៅ សន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩៧ ចុះថ្ងៃទី ១៧-៧-៩៤ របស់តុលាការខេត្តបាត់ដំបង ។

៧-ទណ្ឌិតឈ្មោះ ទន គឿន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៦៧ ចុះថ្ងៃទី ២១-៩-៩៤ របស់តុលាការខេត្តបាត់ដំបង ។

៨-ទណ្ឌិតឈ្មោះ ម៉ឹយ ហៀប ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៧៦ ចុះថ្ងៃទី ៩-៨-៩៦ របស់តុលាការខេត្តបាត់ដំបង ។

៩-ទណ្ឌិតឈ្មោះ ពៅ សារិន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥៦ ចុះថ្ងៃទី ១៦-៩-៩៥ របស់តុលាការខេត្តបាត់ដំបង ។

១០-ទណ្ឌិតឈ្មោះ ឆន ឆាន់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២៦ ចុះថ្ងៃទី ១៦-៩-៩៥ របស់តុលាការខេត្តបាត់ដំបង ។

១១-ទណ្ឌិតឈ្មោះ ឌ៉ុយ ខ្សែង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ឆ្នាំ តាមអំណាចសាលក្រមលេខ ១៧៧ ចុះថ្ងៃទី ១៥-១២-៩៧ របស់តុលាការខេត្តបាត់ដំបង ។

១២-ទណ្ឌិតឈ្មោះ សួន សុផានី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ ចុះថ្ងៃទី ២០-០១-៩៩ របស់តុលាការខេត្តបាត់ដំបង ។

១៣-ទណ្ឌិតឈ្មោះ ម៉ុខ ស៊ឹង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៨ ចុះថ្ងៃទី ២៣-៦-៩៤ របស់តុលាការខេត្ត កំពង់ធំ ។

១៤-ទណ្ឌិតឈ្មោះ យូ ជឿន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៧ ចុះថ្ងៃទី ២៩-៧-៩៤ របស់តុលាការខេត្ត កំពង់ធំ ។

១៥-ទណ្ឌិតឈ្មោះ ម៉ាណ រី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៣ ចុះថ្ងៃទី ២៣-៦-៩៥ របស់តុលាការខេត្តកំពង់ធំ ។

១៦-ទណ្ឌិតឈ្មោះ **លុយ ប៉ាត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៣ ចុះថ្ងៃទី ២២-៨-៩៥ របស់តុលាការខេត្តកំពង់ធំ ។

១៧-ទណ្ឌិតឈ្មោះ **ចាន់ ចំរើន ហៅ ចាន់ សារិន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ៤ ចុះថ្ងៃទី ១២-០២-៩៥ របស់តុលាការខេត្តស្វាយរៀង ។

មាត្រា ៤ ._ ត្រូវលើកលែងទោសឲ្យទណ្ឌិតចំនួន ៤ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោម ៖

១-ទណ្ឌិតឈ្មោះ **ឃុត ហេង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៨ ចុះថ្ងៃទី ១១-៧-៩៧ របស់តុលាការខេត្តបាត់ដំបង ។

២-ទណ្ឌិតឈ្មោះ **សុខ ពិសិដ្ឋ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៥២ ចុះថ្ងៃទី ១៧-១២-៩៦ របស់តុលាការខេត្តបាត់ដំបង ។

៣-ទណ្ឌិតឈ្មោះ **ឃូ ម្រួក** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៦ ចុះថ្ងៃទី ៣០-៩-៩៣ របស់តុលាការខេត្តកំពង់ធំ ។

៤-ទណ្ឌិតឈ្មោះ **ឡេង ឡាញ់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ២២ ចុះថ្ងៃទី ១៩-៥-៩៤ របស់តុលាការខេត្ត កំពង់ធំ ។

មាត្រា ៥ ._ ព្រះរាជក្រឹត្យនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

មាត្រា ៦ ._ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះឲ្យបានសំរេចជាស្ថាពរ ។

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែ ឧសភា ឆ្នាំ ២០០០

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

## ព្រះរាជក្រឹត្យ នស/រកត/០៥០០/១០២

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ២០/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០០

**ត្រាស់បង្គាប់**

មាត្រា ១ ._ តែងតាំង :

-ឯកឧត្តម ស៊ឹម សារ៉ាត់ ជាអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

-ឯកឧត្តម ហង្ស សុត ជាអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

មាត្រា ២ ._ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឲ្យបានសំរេច ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០០

ព្រះហស្ថលេខា

នរោត្តម សីហនុ

★★★

## ព្រះរាជក្រឹត្យ នស/រកត/០៥០០/១០៣

## ស្តីពី

## លក្ខន្តិកៈដោយឡែក

## នៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទទួលការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១២ ខែឧសភា ឆ្នាំ ២០០០

## ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

ត្រូវបានបង្កើតក្របខ័ណ្ឌលេខាធិការរដ្ឋបាលរបស់ ដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ ខ ដូចបានចែងក្នុងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

**មាត្រា ២ .-**

ក្របខ័ណ្ឌលេខាធិការរដ្ឋបាល ដែលជាកម្មវត្ថុនៃលក្ខន្តិកៈដោយឡែកសំរាប់ក្របខ័ណ្ឌលេខាធិការរដ្ឋបាលនេះ ស្ថិតនៅក្រោមឱវាទរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដែលប្រមូលផ្តុំមន្ត្រីរាជការធ្វើការងាររដ្ឋបាលសំរាប់បណ្តាក្រសួង ស្ថាប័ន នានា ។ ឯការវិវត្តន៍របស់មន្ត្រីម្នាក់ៗ គឺស្ថិតនៅក្រោមក្រសួង ស្ថាប័នសាមី ។

មិនត្រូវបានអនុញ្ញាតអោយបង្កើតក្របខ័ណ្ឌសំរាប់ធ្វើការងារ លេខាធិការរដ្ឋបាលផ្សេងពីក្របខ័ណ្ឌលេខាធិការរដ្ឋបាលឡើយ លើកលែងតែក្រសួងមហាផ្ទៃ ។

**មាត្រា ៣ .-**

មន្ត្រីនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល មានឧបនិស្ស័យសំរាប់បំពេញមុខតំណែងក្នុងលេខាធិការដ្ឋាននិងការទទួលភ្ញៀវ ព្រមទាំងមុខងាររដ្ឋបាលធម្មតាទាំងឡាយដែលតម្រូវអោយមានទេពកោសល្យបច្ចេកទេស ឬការយល់ដឹងក្នុងការអនុវត្តន៍ជាក់ស្តែង ។ មន្ត្រីនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល ក៏អាចមានឧបនិស្ស័យសំរាប់ត្រួតពិនិត្យលើការងាររបស់បុគ្គលិកនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលផងដែរ ។ មន្ត្រីនៃក្របខ័ណ្ឌលេខាធិ ការរដ្ឋបាល ត្រូវដាក់អោយបំពេញមុខងារក្នុងអង្គភាពរដ្ឋបាលកណ្តាល ឬ ខេត្តក្រុង ស្របតាមមាត្រា ៥ នៃ ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។ មន្ត្រីក្នុងក្របខ័ណ្ឌនេះ ក៏មានឧបនិស្ស័យសំរាប់បំពេញមុខតំណែង នៅក្នុងគ្រឹះស្ថានសាធារណៈរដ្ឋបាលផងដែរ ។

## ជំពូកទី ២
## ឋានន្តរស័ក្តិ

មាត្រា ៤ ._

ក្របខ័ណ្ឌលេខាធិការរដ្ឋបាល ៣-ឋានន្តរស័ក្តិ :

-នាយលេខាធិការរដ្ឋបាល : មាន ០៦ ថ្នាក់

-លេខាធិការរដ្ឋបាលដើមខ្សែ : មាន ១០ ថ្នាក់

-លេខាធិការរដ្ឋបាល : មាន ១៤ ថ្នាក់ ។

## ជំពូកទី ៣
## ការជ្រើសរើស

មាត្រា ៥ ._

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌលេខាធិការរដ្ឋបាល ត្រូវធ្វើឡើងតាមរបៀបការប្រឡងប្រជែង ដែលរៀបចំឡើងដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដោយមានការចូលរួមពីស្ថាប័នសាមី ក្នុងចំណោមបេក្ខជនមន្ត្រីរាជការ និង ឬក្នុងចំណោមសិស្ស និស្សិត ។ ចំនួនតំណែងក្នុងការជ្រើសរើស សំរាប់បេក្ខជនជាមន្ត្រីរាជការ និងសំរាប់បេក្ខជនជាសិស្ស និស្សិតត្រូវកំណត់ឡើងដោយរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មាត្រា ៦ ._

ការប្រឡងប្រជែងក្នុងចំណោមសិស្ស និស្សិត ត្រូវបើកចំហចំពោះបេក្ខជនដែលមានអាយុច្រើនបំផុត ២៥ ឆ្នាំ គិតមកដល់ថ្ងៃប្រឡង ហើយដែលមានសញ្ញាប័ត្រទាបបំផុតសមមូលមធ្យមសិក្សាប័ត្រភាគទី ២ ។ អាយុនេះ អាចរំកិល ពី ២៥ ឆ្នាំឡើងដល់ ៣០ ឆ្នាំ ស្របតាមមាត្រា១១ នៃលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

ការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវបើកចំហចំពោះមន្ត្រីរាជការទាំងឡាយ ស្ថិតក្នុងក្របខ័ណ្ឌ ប្រភេទ ឃ ដែលបានបំពេញការងារ ៥ ឆ្នាំ ពេញលេញក៏ងតិចរួចមកហើយ ។ ចំពោះមន្ត្រីក្នុងក្របខ័ណ្ឌ ដែលមានសញ្ញាប័ត្រសមមូលនឹងមធ្យមសិក្សាប័ត្រភាគទី ២ អាចប្រឡងប្រជែងចូលក្នុងក្របខ័ណ្ឌនេះបាន ដោយពុំគិតលក្ខខ័ណ្ឌអតីតភាពការងារ និងអាយុឡើយ ។

## ជំពូកទី ៤
## កម្មសិក្សា សាកល្បង និង ការតាំងស៊ប់

មាត្រា ៧ ._

បេក្ខជនដែលត្រូវបានជ្រើសរើស តាមរបៀបការប្រឡងប្រជែង ក្នុងចំណោមមន្ត្រីរាជការ និង ឬ ក្នុងចំណោម សិស្ស និស្សិត ចាំបាច់ត្រូវឆ្លងកាត់របៀបពេលធ្វើកម្មសិក្សាមួយ ដែលមានរយៈពេលដូចខាងក្រោមនេះ ៖

១- ១២ ខែ ចំពោះមន្ត្រីរាជការដែលត្រូវបានជ្រើសរើសចេញមកពីសិស្ស និស្សិត ។

២- ៦ ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ហើយដែលពីមុននេះពុំស្ថិតក្នុងក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ។

ចំពោះមន្ត្រី ដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការផ្សេងៗ ដែលពីមុននេះស្ថិតក្នុងក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលពុំចាំបាច់ឆ្លងកាត់កម្មសិក្សាសាកល្បងឡើយ ។

ក្រោយពេលធ្វើកម្មសិក្សាសាកល្បង មន្ត្រីដែលចែងក្នុងចំណុចទី១ និងទី២ ខាងលើ ត្រូវបានតាំងស៊ប់ក្នុងឋានន្តរស័ក្តិលេខាធិការរដ្ឋបាល ឬ ក្នុងករណីចាំបាច់អាចត្រូវបានអនុញ្ញាតអោយធ្វើកម្មសិក្សាបន្តបន្ថែមដែលមានរយៈពេលអតិបរមាត្រឹម ១២ ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី ១ និង ៦ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី ២ ។ មន្ត្រីដែលពុំមានបានទទួលជោគជ័យក្នុងការធ្វើកម្មសិក្សាបន្ថែមនេះ ត្រូវបានលុបឈ្មោះចោលប្រសិនបើចេញមកពីសិស្ស និស្សិត ឬ មួយបញ្ជូលទៅក្របខ័ណ្ឌដើមរបស់ខ្លួនវិញ ប្រសិនបើចេញមកពីមន្ត្រីរាជការ ដោយគិតបញ្ចូលរយៈរាប់អតីតភាពការងារ ។ ករណីខាងលើទាំងនេះត្រូវសំរេចដោយប្រកាសរបស់ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ តាមសំណើរបស់ក្រសួង ស្ថាប័នសាមីដោយបញ្ជាក់នូវមូលហេតុ ។

មន្ត្រីលេខាធិការរដ្ឋបាល ដែលបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមសិស្ស និស្សិត ត្រូវបញ្ចូលទៅក្នុងថ្នាក់លេខ ១៤ នៃឋានន្តរស័ក្តិលេខាធិការរដ្ឋបាល ។

មន្ត្រីលេខាធិការរដ្ឋបាល ដែលបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវបញ្ចូលទៅក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់លើបន្ទាប់ ពីសន្ទស្សន៍ចាស់របស់សាមីខ្លួន ។

ការតែងតាំងជាមន្ត្រីលេខាធិការរដ្ឋបាលកម្មសិក្សា និងការតាំងស៊ប់ក្នុងឋានន្តរស័ក្តិលេខាធិការរដ្ឋបាលនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល ត្រូវធ្វើឡើងដោយប្រកាសរបស់ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈតាមសំណើរបស់ស្ថាប័នសាមី ។

## ជំពូកទី ៥
## ការតែងតាំង

**មាត្រា ៨ .-**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌលេខាធិការរដ្ឋបាលរួចហើយ មន្ត្រីរាជការទាំងនេះ អាចត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរណាមួយ ដែលស្របជាមួយឋានន្តរស័ក្តិរបស់ខ្លួន ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមី តាមបែបបទដូចបានកំណត់ក្នុងមាត្រា ២៤ នៃព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ។

មាត្រា ៩ ._

មន្ត្រីនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាលអាចផ្លាស់ប្តូរ ពីក្រសួង ស្ថាប័នមួយ ទៅក្រសួង ស្ថាប័នមួយទៀត តាមការស្នើសុំរបស់សាមីខ្លួន ឬ តាមតម្រូវការការងារ ដោយមានការឯកភាពរបស់ក្រសួង ស្ថាប័នសាមីទាំងពីរ និងដោយមានការយល់ព្រមពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

ការផ្លាស់ប្តូរនេះជាគោលការណ៍ អាស្រ័យដោយតំណែងដែលមាននៅទំនេរ ក្នុងក្រសួង ស្ថាប័នមួយទៀត ឬដោយសំណូមពរការងារចាំបាច់ ។

## ជំពូកទី ៦
## ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរស័ក្តិ

មាត្រា ១០ ._

មន្ត្រីនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល ត្រូវបានតម្លើងថ្នាក់ទៅតាមលក្ខខ័ណ្ឌដូចបានចែងក្នុងមាត្រា ២០ និងមាត្រាបន្តបន្ទាប់នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

លក្ខណៈសម្បត្តិជាមូលដ្ឋានដែលត្រូវពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោម ៖

-គោរពវិន័យការងារបានត្រឹមត្រូវ

-សម្រេចបានល្អនូវភារកិច្ចដែលប្រគល់អោយ

-មានសីលធម៌ល្អ ។

ការឡើងថ្នាក់ នៃអ្នករាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង ១ ភាគ ៤ តាមវេនអតីតភាព ហើយត្រូវសំរេចដោយប្រកាសរបស់ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មាត្រា ១១ ._

គោលការណ៍នៃការតម្លើងឋានន្តរស័ក្តិ ត្រូវតម្លើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬក្នុងករណីចាំបាច់ត្រូវតម្លើងទៅក្នុងថ្នាក់ ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើបន្ទាប់ ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី ។

ការតម្លើឋានន្តរស័ក្តិ ត្រូវអនុវត្តអោយបានស្របជាមួយចំនួនតំណែង ដែលមានទំនេរនៅក្នុងឋានន្តរស័ក្តិនោះ ហើយត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬ តាមរយៈការប្រឡងប្រជែងដោយរក្សាគោលការណ៍ភាគរយ ៖

-ឋាននន្តរស័ក្តិនាយលេខាធិការរដ្ឋបាល = ៥ ភាគរយ

-ឋាននន្តរស័ក្តិលេខាធិការរដ្ឋបាលដើមខ្សែ = ២៥ ភាគរយ

-ឋាននន្តរស័ក្តិលេខាធិការរដ្ឋបាល = ៧០ ភាគរយ ។

ការតម្លើងឋាននន្តរស័ក្តិ ត្រូវសំរេចតាមប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មាត្រា ១២ ._

អាចតម្លើងទៅក្នុងឋាននន្តរស័ក្តិលេខាធិការរដ្ឋបាលដើមខ្សែ គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋាននន្តរស័ក្តិលេខាធិការរដ្ឋបាល ។ អាចតម្លើងទៅក្នុងឋាននន្តរស័ក្តិនាយលេខាធិការរដ្ឋបាល គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ៧ នៃឋាននន្តរស័ក្តិលេខាធិការរដ្ឋបាលដើមខ្សែ ។

មាត្រា ១៣ ._

សន្ទស្សន៍សំរាប់ថ្នាក់ ក្នុងឋាននន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល និងតម្លៃឯកតា នៃសន្ទស្សន៍ព្រមទាំងរបបលាភការផ្សេងៗទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

## ជំពូកទី ៧

## បទប្បញ្ញត្តិដោយឡែក

មាត្រា ១៤ ._

មន្ត្រីក្របខ័ណ្ឌលេខាធិការរដ្ឋបាល ត្រូវដាក់អោយចូលនិវត្តន៍ពេលដល់អាយុ ៥៥ ឆ្នាំ ។

ចំពោះការដាក់អោយចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

មាត្រា ១៥ ._

មន្ត្រីនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល ដែលមានសញ្ញាប័ត្រមធ្យមសិក្សាប័ត្រភាគទី ២ + ២ ឆ្នាំ សិក្សាដោយមានសញ្ញាប័ត្រ ត្រូវបានតម្លើងថ្នាក់មួយថ្នាក់ជាស្វ័យប្រវត្តិ ។

## ជំពូកទី ៨

## អន្តរប្បញ្ញត្តិ

មាត្រា ១៦ ._

ចំនួនដំបូងនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល ត្រូវកសាងចេញពីសមាហរណកម្មនៃមន្ត្រីទាំងឡាយដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌនៅរដ្ឋបាលកណ្តាល និង ខេត្ត ក្រុង ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

មាត្រា ១៧ ._

រាល់បទប្បញ្ញត្តិណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ១៨ ._

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

រាជធានីភ្នំពេញ , ថ្ងៃទី ៣១ខែ ឧសភា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីជំរាបជូនសម្តេច

នាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ហត្ថលេខា

ពេជ្រ ប៊ុនធីន

★★★

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ២៧ អនក្រ.បក

### ស្តីពីការបង្កើតគណកម្មាធិការជាតិរៀបចំកម្មវិធីជាតិនៃសកម្មភាពអភិវឌ្ឍន៍កម្ពុជា

****

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការ ប្រព្រឹត្តិទៅរបស់ក្រសួងផែនការ

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

**សំរេច**

មាត្រា ១ .-

បង្កើតគណៈកម្មាធិការជាតិរៀបចំកម្មវិធីជាតិនៃសកម្មភាពអភិវឌ្ឍន៍កម្ពុជា ដែលហៅកាត់ថា គ.ជ.ស.ជ ដើម្បីគ្រប់គ្រងការរៀបចំឯកសាររាយការណ៍ចូលរួមប្រជុំសន្និសីទសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍន៍ ហៅ UNCTAD ។

មាត្រា ២ .-

គ.ជ.ស.ជ មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងផែនការ | ជាប្រធាន |
| ២-ឯកឧត្តមរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ជាអនុប្រធាន |
| ៣-ឯកឧត្តមអគ្គលេខាធិការ ក.អ.ក | ជាអនុប្រធាន |
| ៤-ឯកឧត្តមរដ្ឋលេខាធិការក្រសួងផែនការ | ជាអនុប្រធានអចិន្ត្រៃយ៍ |
| ៥-តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ៦-តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ជាសមាជិក |
| ៧-តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៨-តំណាងក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៩-តំណាងក្រសួង បរិស្ថាន | ជាសមាជិក |
| ១០-តំណាងក្រសួង រៀបចំដែនដី នគរូបនីយកម្មនិងសំណង់ | ជាសមាជិក |
| ១១-តំណាងក្រសួង ធនធានទឹក និងឧតុនិយម | ជាសមាជិក |
| ១២-តំណាងក្រសួងទេសចរណ៍ | ជាសមាជិក |
| ១៣-តំណាងក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល | ជាសមាជិក |
| ១៤-តំណាងក្រសួង សាធារណការ និងដឹកជញ្ជូន | ជាសមាជិក |
| ១៥-តំណាងក្រសួង ប្រៃសណីយ៍ និងទូរគមនាគមន៍ | ជាសមាជិក |
| ១៦-តំណាងក្រសួង សុខាភិបាល | ជាសមាជិក |
| ១៧-តំណាងក្រសួង អប់រំ យុវជន និងកីឡា | ជាសមាជិក |

១៨-តំណាងក្រសួង អភិវឌ្ឍន៍ជនបទ ជាសមាជិក

១៩-តំណាងក្រសួង កសិកម្ម រុក្ខាប្រមាញ់និងនេសាទ ជាសមាជិក

២០-តំណាងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទាជាសមាជិក

២១-តំណាង កិច្ចការនារី និង អតីតយុទ្ធជន ជាសមាជិក

២២-តំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ជាសមាជិក

២៣-ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ក្រសួងផែនការ លេខាធិការ

មាត្រា ៣ ._

គ.ជ.ស.ជ មានភារកិច្ចដូចតទៅ :

-សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំឯកសារកម្មវិធីជាតិនៃសកម្មភាពក្នុងការស្តារឡើងវិញការកសាងនិងអភិវឌ្ឍន៍កម្ពុជាស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល

-ធ្វើទំនាក់ទំនងផ្ទាល់ជាមួយអគ្គលេខាធិការ UNCTAD និងអង្គការអន្តរជាតិនានាដើម្បីដោះស្រាយការងារពាក់ព័ន្ធ

-រាយការណ៍អំពីលទ្ធផលការងារនិងផ្តល់យោបល់ជាយុទ្ធសាស្ត្រ ដើម្បីសុំសេចក្តីសំរេចពីរាជរដ្ឋាភិបាល ។

មាត្រា ៤ ._

សមាជិក គ.ជ.ស.ជ ត្រូវចូលរួមប្រជុំតាមការអញ្ជើញ និងក្រោមការដឹកនាំរបស់ប្រធាន ឬ អនុប្រធានក្នុងករណីអវត្តមានរបស់ប្រធាន ។ ក្នុងករណីសមាជិកណាម្នាក់មិនបានឆ្លើយតបនឹងការអញ្ជើញដោយជាប់រវល់ភារកិច្ចត្រូវចាត់តំណាងដែលមានសិទ្ធិសំរេច ឲ្យចូលរួមប្រជុំជំនួស ។

មាត្រា ៥ ._

គ.ជ.ស.ជ មានលេខាធិការដ្ឋានដែលមានទីតាំងនៅក្រសួងផែនការ ហើយមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងផែនការក្នុងករណីចាំបាច់ និងមានសិទ្ធិអញ្ជើញវរជនមានការពិសោធន៍និងអ្នកជំនាញឯកទេសមកពីគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធអោយចូលរួមប្រជុំការងារក្នុងឋានៈជាជំនួយការខាងផ្នែកបច្ចេកទេស ។

លេខាធិការដ្ឋាន គ.ជ.ស.ជ ត្រូវដឹកនាំដោយឯកឧត្តមរដ្ឋលេខាធិការក្រសួងផែនការ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ស.ជ ។

មាត្រា ៦ ._

គ.ជ.ស.ជ ត្រូវរៀបចំថវិកាដោយឡែកមួយដែលជាឧបសម្ព័ន្ធថវិការបស់ក្រសួងផែនការ ដើម្បីដំណើរការងារជាក់ស្តែង ។

មាត្រា ៧ ._

បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយទៅនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី រដ្ឋលេខាធិការនិង តំណាងក្រសួងនិងរដ្ឋលេខាធិការដ្ឋានដែលមានចែងក្នុងមាត្រា២ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះឲ្យបានសំរេច ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែឧសភា ឆ្នាំ ២០០០

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី
ដើម្បីសុំហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងផែនការ**
**ឆាយ ថន**

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ២៨ អនក្រ.បក**
**ស្តីពីការបង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជា**

****

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- យោងតាមសភាពការណ៍ចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

**សំរេច**

**មាត្រា ១ ._** បង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជា ដែលមានសមាសភាពចំរុះមកពីបណ្តាក្រសួងស្ថាប័ននានា ដើម្បីជួយរាជរដ្ឋាភិបាល និងក្រសួងទេសចរណ៍ ក្នុងការគ្រប់គ្រងដឹកនាំការអភិវឌ្ឍន៍វិស័យទេសចរណ៍ទូទាំងប្រទេស ។

អាជ្ញាធរជាតិទេសចរណ៍កម្ពុជាមានអក្សរកាត់ថា " អជទក " ។

**មាត្រា ២ ._** អាជ្ញាធរជាតិទេសចរណ៍កម្ពុជា រួមមានសមាសភាព :

| | | |
|---|---|---|
| ១-**ឯកឧត្តម សុខ អាន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | | ជាប្រធាន |
| ២-**សម្តេចព្រះរាម នរោត្តម បុប្ផាទេវី** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | | ជាអនុប្រធាន |
| ៣-**ឯកឧត្តម វណ្ណ ម៉ូលីវណ្ណ** ប្រធានអគ្គនាយកអាជ្ញាធរអប្សរា | | ជាអនុប្រធាន |
| ៤-**ឯកឧត្តម វេង សេរីវុឌ្ឍ** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | | ជាអនុប្រធាន |

៥-ឯកឧត្តម ថោង ខុន រដ្ឋលេខាធិការក្រសួងទេសចរណ៍ ជាសមាជិកប្រចាំការ
៦-ឯកឧត្តម ព្រុំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាសមាជិក
៧-ឯកឧត្តម អ៊ុង គីមអន រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក
៨-ឯកឧត្តម ខៀវ កាញារិទ្ធ រដ្ឋលេខាធិការក្រសួងពត៌មាន ជាសមាជិក
៩-ឯកឧត្តម គង់ វិបុល រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក
១០-ឯកឧត្តម ត្រាំ អ៊ីវតឹក រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន ជាសមាជិក
១១-ឯកឧត្តម ច័ន្ទ តុនអ៊ីវ រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ជាសមាជិក
១២-ឯកឧត្តម ឆាន់ សាផាន់ រដ្ឋលេខាធិការក្រសួងបរិស្ថាន ជាសមាជិក
១៣-ឯកឧត្តម នឹម ថូត រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាល វិជ្ជាជីវៈ និងយុវនីតិសម្បទា ជាសមាជិក
១៤-ឯកឧត្តម កែវ សាផល អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ជាសមាជិក
១៥-ឯកឧត្តម សុ ម៉ាវី អគ្គនាយកក្រសួងទេសចរណ៍ ជាអគ្គលេខាធិការ

មាត្រា ៣ . អាជ្ញាធរជាតិទេសចរណ៍កម្ពុជា មានតួនាទី និងភារកិច្ចដូចខាងក្រោម :

-ជំនួយអោយរាជរដ្ឋាភិបាលក្នុងការរៀបចំកសាងគោលនយោបាយ ផែនការអភិវឌ្ឍន៍ ការត្រួតពិនិត្យ និងសំរបសំរួលការងារអនុវត្ត ការអភិវឌ្ឍន៍វិស័យទេសចរណ៍ ។

-ត្រៀមការងារជូនរាជរដ្ឋាភិបាលដើម្បីសំរេចលើគំរោងអភិវឌ្ឍន៍ ឬវិនិយោគនានានៃវិស័យទេសចរណ៍ ។

-ណែនាំក្រសួងទេសចរណ៍ក្នុងការតាមដានបញ្ជាក់ និងឆ្លុះបញ្ចាំងលទ្ធផលនៃការអនុវត្តន៍គោលនយោបាយ សេចក្តីសំរេចចិត្ត ព្រមទាំងផែនការអនុវត្តទាំងឡាយដែលទាក់ទងដល់កិច្ចអភិវឌ្ឍន៍វិស័យទេសចរណ៍ ។

-កំណត់កំរិតអាទិភាព សំរាប់កិច្ចអភិវឌ្ឍន៍វិស័យទេសចរណ៍ និងការងារទីផ្សារទេសចរណ៍ ។

-សំរបសំរួលទំនាក់ទំនងស្ថាប័នសាធារណៈនានា គ្រឹះស្ថានឯកជននានា និងសមាគមទាំងឡាយដែលប្រកបអាជីកម្មវិស័យទេសចរណ៍ លើការអនុវត្តន៍ គោលនយោបាយ ផែនការ ដែលជាប់ទាក់ទងក្នុងការអភិវឌ្ឍន៍វិស័យទេសចរណ៍ដោយឈរលើមូលដ្ឋាននៃផែនការអភិវឌ្ឍន៍ជាតិ ។

មាត្រា ៤ ._ អាជ្ញាធរជាតិទេសចរណ៍ មានសិទ្ធិទទួលនូវមធ្យោបាយសំភារៈទេសចរណ៍ និង ប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាល ឬគ្រឹះស្ថានឯកជននានា សំរាប់កិច្ចដំណើរការ ការងាររបស់ខ្លួន និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៥ ._ រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៦ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកនាំ

ជញ្ជូន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ និង សម្ដេច ឯកឧត្តមដែលមាននាមក្នុងមាត្រា២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៧ ._** អនុក្រឹត្យនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ២៩ អនក្រ.តត

## ស្ដីពីការបង្វែរឥណទាន

****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំង នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ /០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣
- បានឃើញច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦
- បានឃើញច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខនស/រកម/១២៩៩/១៥ចុះថ្ងៃទី២៥ខែធ្នូឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលស្ដីពីការបែងចែកឥណទានចំណាយទៅតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០

- បានឃើញលិខិតលេខ ៧៧ អយក.ស្វរ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ ២០០០ របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង និងចំណារបញ្ជូនលេខ ២៥ អយក.ប ចុះថ្ងៃទី០៧ ខែ មិនា ឆ្នាំ២០០០ របស់ឯកឧត្តមរដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា
- យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

មាត្រា ១ .- ត្រូវបានអនុញ្ញាតអោយបង្វែរឥណទានថវិកាចំនួន ៩៦.២០០.០០០រៀល ( កៅសិបប្រាំមួយលានពីររយពាន់រៀលគត់ ) ពីជំពូក ១០ ( ប្រាក់បៀវត្ស និងប្រាក់បំណាច់ ) ទៅជំពូក៣១ ( អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ចនិង វប្បធម៌ ) របស់មន្ទីរអប់រំយុវជន និងកីឡាខេត្តស្វាយរៀង នៃក្រសួងអប់រំ យុវជន និងកីឡា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដូចខាងក្រោម ៖

| ជំពូក | ឥណទានដើមឆ្នាំ | ការប្រែប្រួលឥណទាន | | ស្ថានភាពឥណទានថ្មី |
|---|---|---|---|---|
| | | កើន | ថយ | |
| ១០ | ៥.១២២,០ | - | ៩៦,២ | ៥.០២៥,៨ |
| ៣១ | ១០៦,០ | ៩៦,២ | | ២០២,២ |
| សរុប | ៥.២២៨,០ | ៩៦,២ | ៩៦,២ | ៥.២២៨,០ |

មាត្រា ២ .- ឥណទានថវិកាក្នុងមាត្រា១ខាងលើ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ របស់មន្ទីរអប់រំយុវជន និងកីឡាខេត្តស្វាយរៀង នៃក្រសួងអប់រំយុវជន និងកីឡា សំរាប់ចំណាយឧបត្ថម្ភនិវត្តជនចំនួន ៨៨.៥២៦.៤៥០រៀល និងសំរាប់ចំណាយឧបត្ថម្ភគោលនយោបាយមន្ត្រីរាជការអរណោះភាព ចំនួន ៧.៦៧៣.៥៥០រៀល ។

មាត្រា ៣ .- ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ឯកឧត្តមទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តមទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាម ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# អនុក្រឹត្យលេខ ៣០ អនក្រ.បក
## ស្តីពី ការរៀបចំនិងការប្រព្រឹត្តិទៅ
## របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០០/០០៧ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- តាមការឯកភាពពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៩

## សំរេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះ កំណត់ការរៀបចំនិងការប្រព្រឹត្តិទៅរបស់អាជ្ញាធរជាតិប្រយុទ្ធ នឹងជំងឺអេដស៍ហៅកាត់ អ.ជ.ប.ជ.អ ក្នុងគោលដៅបង្ការទប់ស្កាត់ការចម្លងមេរោគអេដស៍ និងបន្ថយល្បឿនការរីករាលដាលនៃជំងឺអេដស៍ នៅព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ២
## បេសកកម្ម និងរចនាសម្ព័ន្ធ

**មាត្រា ២ .-**

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបានរាជរដ្ឋាភិបាលប្រគល់តួនាទីជូនធ្វើជាសេនាធិការក្នុងកិច្ចទទួលខុសត្រូវរួម លើវិធានការការពារនិងព្យាបាលព្រមទាំងទប់ស្កាត់ការរីករាលដាល នៃជំងឺអេដស៍ ហើយមានភារកិច្ចដូចតទៅ :

១-លើកគោលនយោបាយជាតិប្រយុទ្ធនឹងជំងឺអេដស៍

២-រៀបចំយុទ្ធសាស្ត្រសំរាប់អនុវត្តគោលនយោបាយជាតិ

៣-សំរបសំរួល ណែនាំ និងបង្កលក្ខណៈអនុវត្តកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ នៅតាមបណ្តាស្ថាប័នពាក់ព័ន្ធនានា អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងក្រុមហ៊ុនឯកជនអោយមាននិរន្តរភាព

៤-ស្វែងរកជំនួយពីគ្រប់មូលដ្ឋានជាតិនិងអន្តរជាតិ ដើម្បីគាំទ្រការអនុវត្តន៍ផែនការជាតិប្រយុទ្ធនឹងជំងឺអេដស៍

៥-លើកយោបល់ជូនរាជរដ្ឋាភិបាល អំពីបញ្ហាទាំងឡាយដែលទាក់ទងនឹងសភាពការនៃជំងឺអេដស៍

៦-ផ្លាស់ប្តូរបច្ចេកទេស និងបទពិសោធន៍ជាមួយប្រទេសទាំងឡាយណាដែលមានបញ្ហាអេដស៍

៧-ទ្រទ្រង់ សំរបសំរួល និងសហការធ្វើការស្រាវជ្រាវអេពីដេមីស្សាស្ត្រ និងស្រាវជ្រាវផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនិងសង្គម នៃជំងឺអេដស៍

៨-ផ្តល់យោបល់ ណែនាំស្តីពីវិធានការដែលមានចែងក្នុងមាត្រា២ ខាងលើនៃអនុក្រឹត្យនេះដល់មន្ទីរពិសោធន៍ មន្ទីរពេទ្យនិងកន្លែងថែទាំ ព្យាបាល អ្នកផ្ទុកមេរោគអេដស៍ អ្នកជំងឺអេដស៍

៩-ពិនិត្យអនុម័តលើគំរោងកម្មវិធីអប់រំ ដែលត្រូវធ្វើការផ្សព្វផ្សាយនៅតាមក្រសួង ស្ថាប័នសាលារៀនតាមវិទ្យុ ទូរទស្សន៍ និងលើកថ្ងៃជំងឺអប់រំដោយផ្ទាល់

១០-ទទួលខុសត្រូវរៀបចំច្បាប់ និងចេញលិខិតបទដ្ឋានទាំងឡាយស្តីពីការត្រួតពិនិត្យនិងការអនុវត្តន៍បទប្បញ្ញត្តិផ្សេងៗដែលទាក់ទងនឹងជំងឺអេដស៍ ដោយសង្កត់ធ្ងន់លើសិទ្ធិមនុស្ស ។

មាត្រា ៣ .-

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| ១-ប្រធាន | ១ រូប | |
| ២-អនុប្រធានប្រចាំការ | ១ រូប | |
| ៣-អនុប្រធានជំនួយការ | ១ រូប | |
| ៤-អគ្គលេខាធិការ | ១ រូប | |
| ៥-ទីប្រឹក្សា | ៣ រូប | |
| ៦-រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | | ១ រូប ជាសមាជិក |
| ៧-រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា | | ១ រូប ជាសមាជិក |
| ៨-រដ្ឋលេខាធិការក្រសួងអប់រំ យុវជននិងកីឡា | | ១ រូប ជាសមាជិក |
| ៩-រដ្ឋលេខាធិការក្រសួងការពារជាតិ | | ១ រូប ជាសមាជិក |
| ១០-រដ្ឋលេខាធិការក្រសួងសុខាភិបាល | | ១ រូប ជាសមាជិក |
| ១១-រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | | ១ រូប ជាសមាជិក |
| ១២-រដ្ឋលេខាធិការក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន | | ១ រូប ជាសមាជិក |
| ១៣-រដ្ឋលេខាធិការក្រសួងពត៌មាន | | ១ រូប ជាសមាជិក |
| ១៤-រដ្ឋលេខាធិការក្រសួងទេសចរណ៍ | | ១ រូប ជាសមាជិក |

១៥-រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា ១ រូប ជាសមាជិក
១៦-រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ១ រូប ជាសមាជិក
១៧-រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ១ រូប ជាសមាជិក
១៨-រដ្ឋលេខាធិការក្រសួងផែនការ ១ រូប ជាសមាជិក
១៩-អភិបាលរងរាជធានីភ្នំពេញ ១ រូប ជាសមាជិក
២០-អភិបាលរងខេត្ត ក្រុងនិមួយៗ ១ រូប ជាសមាជិក

មាត្រា ៤ ._

រដ្ឋមន្ត្រីក្រសួងសុខាភិបាល ជាប្រធាននៃ អ.ជ.ប.ជ.អ ដោយប្រស្ម័យប្រវត្តិ ។

ប្រធានប្រគល់សិទ្ធិគ្រប់គ្រងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អោយអនុប្រធានប្រចាំការ ។

ប្រធានទទួលខុសត្រូវ លើការងារ អ.ជ.ប.ជ.អ

-ធ្វើជាអធិបតីភាពក្នុងអង្គប្រជុំ អ.ជ.ប.ជ.អ

-ដឹកនាំពិភាក្សា និងប្តូរសម្រេចគំនិតរបស់អង្គប្រជុំ អ.ជ.ប.ជ.អ

-កោះប្រជុំសាមញ្ញ ឬក្នុងករណីចាំបាច់ប្រជុំវិសាមញ្ញនៃអង្គប្រជុំ អ.ជ.ប.ជ.អ

មាត្រា ៥ ._

អនុប្រធានប្រចាំការ អ.ប.ជ.អ មានឋានៈស្មើនឹងរដ្ឋមន្ត្រី មានតួនាទីនិងភារកិច្ចដូចតទៅ :

-ទទួលខុសត្រូវជាទូទៅលើការងារ អ.ជ.ប.ជ.អ

-ទទួលខុសត្រូវក្នុងការដឹកនាំ និងគ្រប់គ្រងការងារប្រចាំថ្ងៃរបស់ អ.ជ.ប.ជ.អ

-ធ្វើជាអធិបតីក្នុងអង្គប្រជុំ អ.ជ.ប.ជ.អ ក្នុងករណីអវត្តមានរបស់ប្រធាន និងចុះហត្ថលេខាលើកំណត់ហេតុនិងសេចក្តីជូនដំណឹង នៃអង្គប្រជុំរបស់ អ.ជ.ប.ជ.អ

-ទទួលបន្ទុកការងាររបស់រូបអន្តរក្រសួង រវាង អ.ជ.ប.ជ.អ ជាមួយក្រសួងស្ថាប័ននានា នៃរាជរដ្ឋាភិបាល

-ទទួលបន្ទុកទំនាក់ទំនង និងសំរបសំរួលធ្វើសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ដែលពាក់ព័ន្ធក្នុងវិស័យអេដស៍ ។

មាត្រា ៦ ._

ក្នុងការបំពេញភារកិច្ចទាំងឡាយនេះ អនុប្រធានប្រចាំការ មានអនុប្រធានជំនួយការមួយរូបដែលមានឋានៈស្មើរដ្ឋលេខាធិការ និងទីប្រឹក្សាមួយចំនួន ។

មាត្រា ៧ ._

អ.ជ.ប.ជ.អ បើកសម័យប្រជុំពេញអង្គរបស់ខ្លួនយ៉ាងតិចពីរដងក្នុងមួយឆ្នាំ ក្រោមអធិបតីភាពរបស់ប្រធាន ឬអនុប្រធានប្រចាំការ ក្នុងករណីអវត្តមានរបស់ប្រធាន ។ តំណាងម្ចាស់ជំនួយអាចចូលរួមក្នុងកិច្ចប្រជុំ អ.ជ.ប.ជ.អ ជាអ្នកសង្កេតការណ៍ដែលមិនត្រូវមានចំនួនលើសពីបួននាក់ឡើយ ។

មាត្រា ៨ ._

ដើម្បីបំពេញបាននូវបេសកកម្មរបស់ខ្លួន អ.ជ.ប.ជ.អ មានសិទ្ធិអំពាវនាវចំពេញបទដ្ឋានផ្សេងៗក្នុងវិស័យប្រយុទ្ធនឹងជំងឺអេដស៍ ដែលមានលក្ខណៈជាទូទៅក្តី ជាបុគ្គលក្តី ដែលអាជ្ញាធរគ្រប់ជាន់ថ្នាក់ត្រូវយកទៅអនុវត្តអោយមានប្រសិទ្ធភាព ។

មាត្រា ៩ ._

អ.ជ.ប.ជ.អ មានសិទ្ធិប្រើប្រាស់ ត្រាផ្ទាល់របស់ខ្លួន ។

មាត្រា ១០ ._

រចនាសម្ព័ន្ធ អ.ជ.ប.ជ.អ មានដូចខាងក្រោម :

-ខុទ្ទកាល័យ អ.ជ.ប.ជ.អ

-អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ

-ក្រុមប្រឹក្សាបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ ។

## ជំពូកទី ៣

## ខុទ្ទកាល័យ អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាបច្ចេកទេស

មាត្រា ១១ ._

ខុទ្ទកាល័យ អ.ជ.ប.ជ.អ ទទួលបន្ទុកបេសកកម្ម និងភារកិច្ចទាំងឡាយដែលមានកំណត់តាមបញ្ញត្តិនៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ដូចមានចែងក្នុងមូលបទខាងលើស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន ។

មាត្រា ១២ ._

អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ ចែកចេញជាផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេសមួយចំនួនព្រមទាំងមានក្រុមប្រឹក្សាបច្ចេកទេសមួយ ជាជំនួយការ ។

អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ ត្រូវបានដឹកនាំដោយអគ្គលេខាធិការមួយរូប ដែលអាចអមដោយអគ្គលេខាធិការរងមួយចំនួន តាមការចាំបាច់ ។

ការរៀបចំនិងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ ត្រូវកំណត់ដោយប្រកាស របស់ អ.ជ.ប.ជ.អ ។

មាត្រា ១៣ ._

អគ្គលេខាធិការ អ.ជ.ប.ជ.អ មានតួនាទីនិងភារកិច្ចដូចតទៅ :

-ទទួលបន្ទុកចាត់ចែង គ្រប់គ្រងការងាររបស់អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.ជ.អ

-រៀបចំកម្មវិធីការងារ អ.ជ.ប.ជ.អ និងរៀបចំរបៀបវារៈ និងសំណុំឯកសារផ្សេងៗសំរាប់អង្គប្រជុំ អ.ជ.ប.ជ.អ និងអង្គប្រជុំរបស់ក្រុមប្រឹក្សាបច្ចេកទេស

-រៀបចំកំណត់ហេតុ សេចក្តីជូនដំណើរការប្រជុំរបស់ អ.ជ.ប.ជ.អ និងការប្រជុំរបស់ក្រុមប្រឹក្សាបច្ចេកទេស ដើម្បីដាក់ជូនប្រធាន អ.ជ.ប.ជ.អ ចុះហត្ថលេខា

-រៀបចំរបាយការណ៍ អ.ជ.ប.ជ.អ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ

-រៀបចំប្រកាសព័ត៌មានរបស់ អ.ជ.ប.ជ.អ

-ចូលរួមក្នុងអង្គប្រជុំ អ.ជ.ប.ជ.អ នឹងធ្វើជាអធិបតីក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាបច្ចេកទេស

-បំពេញការងារផ្សេងៗទៀតដែលប្រធាន និងអនុប្រធាន អ.ជ.ប.ជ.អ ប្រគល់អោយ ។

**មាត្រា ១៤ ._**

អគ្គលេខាធិការរងនិមួយៗបំពេញកិច្ចការតាមភារកិច្ច ដែលអគ្គលេខាធិការប្រគល់អោយ ។

**មាត្រា ១៥ ._**

ក្រុមប្រឹក្សាបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ មានសមាជិកជាមន្ត្រីដែលមានបទពិសោធន៍ក្នុងបញ្ហាអេដស៍ មកពីក្រសួងពាក់ព័ន្ធទាំង ១៣ ។

**មាត្រា ១៦ ._**

ក្រុមប្រឹក្សាបច្ចេកទេសនៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ ត្រូវប្រជុំយ៉ាងតិចម្តងក្នុងមួយខែ ក្រោមអធិបតីភាពរបស់អគ្គលេខាធិការនៃ អ.ជ.ប.ជ.អ ដើម្បី :

-រៀបចំយុទ្ធសាស្ត្រសំរាប់អនុវត្តគោលនយោបាយជាតិ ក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ ជំងឺអេដស៍

-រៀបចំផែនការអភិវឌ្ឍន៍តាមបច្ចេកទេស ក្នុងវិស័យអេដស៍

-ណែនាំអនុវត្តយុទ្ធសាស្ត្រដើម្បីឆ្លើយតបដោយប្រសិទ្ធភាព ទៅនឹងតំរូវការនៃស្ថានភាពជំងឺអេដស៍នៅព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៤

## អំពីការអនុវត្តន៍គោលនយោបាយ អ.ជ.ប.ជ.អ

**មាត្រា ១៧ ._**

សមាជិក អ.ជ.ប.ជ.អ ដែលតំណាងអោយក្រសួងទាំង ១៣ រាជធានីភ្នំពេញនិងខេត្ត ក្រុង និមួយៗ ត្រូវទទួលខុសត្រូវចំពោះមុខ អ.ជ.ប.ជ.អ ក្នុងការអនុវត្តន៍គោលនយោបាយតាមយុទ្ធសាស្ត្រ ដែលបានកំណត់ដោយ អ.ជ.ប.ជ.អ ។

**មាត្រា ១៨ ._**

ក្នុងការអនុវត្តន៍ផែនការ ឆ្លើយតបនឹងការរីករាលដាល នៃមេរោគអេដស៍ ជំងឺអេដស៍ អ.ជ.ប.ជ.អ ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយគណកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានីភ្នំពេញ ខេត្ត-ក្រុង និង ខ័ណ្ឌ-ស្រុក ដែលមានស្រាប់ ។

## ជំពូកទី ៥
## ប្រភពធនធាននិងការគ្រប់គ្រងហិរញ្ញវត្ថុ

មាត្រា ១៩ ._

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលជាស្ថាប័នជាតិនៃព្រះរាជាណាចក្រកម្ពុជា មានប្រភពធនធានផ្តល់ផ្គង់ដោយថវិកាជាតិ ក្នុងកញ្ចប់ថវិកានៃក្រសួងសុខាភិបាល សំរាប់វិស័យអេដស៍និងដោយជំនួយពីក្នុង និងក្រៅប្រទេស ។

មាត្រា ២០ ._

រាល់បុគ្គលិករបស់ អ.ជ.ប.ជ.អ ពិជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌអង្គការគណៈ ។

មាត្រា ២១ ._

អគ្គលេខាធិការត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុ ដោយមានការឯកភាពពីនាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាលជូន អ.ជ.ប.ជ.អ រៀងរាល់ត្រីមាស ។ ការត្រួតពិនិត្យគណនេយ្យ ត្រូវប្រគល់ជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលត្រូវបានតែងតាំងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ២២ ._

អ.ជ.ប.ជ.អ មានកាតព្វកិច្ចប្រើប្រាស់ថវិកាដែលបានទទួល ដោយមានប្រសិទ្ធភាព និង និរន្តរភាពក្នុងការបំពេញភារកិច្ចរបស់ខ្លួន ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

មាត្រា ២៣ ._

រាល់អនុក្រឹត្យ និងសេចក្តីសំរេចពីមុន ដែលផ្ទុយនឹងខ្លឹមសារនៃអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ២៤ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត ក្រុង និងមន្ត្រីរាជការ ដែលមានចែងក្នុងមាត្រា ៣ ត្រូវអនុវត្តអោយបានសំរេចនូវអនុក្រឹត្យនេះទៅតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល

និងជាប្រធាន អជបជអ

**ហុង សុនហួត**

***

# អនុក្រឹត្យលេខ ១៧៦ អនក្រ.តត

## ស្ដីពីការជូនមេដាយការងារ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៥/០១ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៩៥ ស្ដីពីការប្រកាសឲ្យប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តកណ្ដាល

### សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយមាសការងារ** ជូនលោកវេជ្ជបណ្ឌិត **ម៉ិន ឡេង** ប្រធានការិយាល័យសុខាភិបាលស្រុកកោះធំ ដែលមានស្នាដៃល្អ ក្នុងការខិតខំស្វែងរកជំនួយ សំរាប់កសាងមណ្ឌលសុខាភិបាល ក្នុងស្រុកកោះធំ ខេត្តកណ្ដាល ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងអភិបាលខេត្តកណ្ដាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យលេខ ១៧៧ អនក្រ.តត

## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

**សំរេច**

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០២ រូប ដែលបានរួមចំណែកស្វែងរកថវិកា ជួយកសាងបានរួច អាគារសិក្សាមួយខ្នង បំពាក់ដោយសំភារៈសិក្សាគ្រប់គ្រាន់ ព្រមទាំងបង្គន់អនាម័យ របងទ្វារ អណ្តូងទឹក នៅក្នុងបរិវេណសាលាបឋមសិក្សា ទួលត្រាច ក្នុងខេត្តកំពង់ស្ពឺ ចំណាយអស់ទឹកប្រាក់ចំនួន ៣០.០០០ ដុល្លារអាមេរិក ដូចមាននាមខាងក្រោម ៖

១- Mrs **HIROKO kOSUGI** ប្រធានអង្គការមូលនិធិ GFC Cambodia

២- លោក **គាំម កុសល** ទីប្រឹក្សាសម្តេច **ហេង សំរិន**

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ១៧៨ អនក្រ.តត

## ស្តីពី ការលុបឈ្មោះ

## មន្ត្រីរាជការចេញពីក្របខ័ណ្ឌរដ្ឋបាលស៊ីវិល នៃក្រសួងមហាផ្ទៃ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់ក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា ១ ._** ត្រូវបានលុបឈ្មោះលោក **ទ៊ុត សូម៉ារឹម** ចេញពីក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល នៃក្រសួងមហាផ្ទៃ ដោយមូលហេតុទទួលមរណភាព ។

**មាត្រា ២ ._** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១៧៩ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

**សម្រេច**

**មាត្រា ១ ._** តែងតាំង :

១-លោក **មាស សារុន** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

២-លោក ម៉ៅ គេង ជាប្រធាននាយកដ្ឋានសិល្បៈ ទស្សនីយភាព

៣-លោកស្រី លន់ សាឌី ជាប្រធាននាយកដ្ឋាន គណនេយ្យ និងហិរញ្ញវត្ថុ

៤-លោក ចន្ទ ទណ្ឌា ជាប្រធាននាយកដ្ឋានសំភារៈ និងបរិក្ខារ

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១៨០ អនក្រ.តត

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសប្រើអោយច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាលេខ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំរេច

មាត្រា ១ ._ ត្រូវបានផ្លាស់ប្តូរភារកិច្ចលោក ណាំ នុំ អភិបាលរងទី ១ ខេត្តសៀមរាប អោយមកទទួលភារកិច្ចជាទីប្រឹក្សាឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ,ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ១៨១ អនក្រ.តត

## ស្តីពីការតែងតាំងអភិបាលរងខេត្ត ក្រួច

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំរេច

**មាត្រា ១ .-** ត្រូវបានតែងតាំងឧត្តមសេនីយ៍ត្រី អ៊ុខ អឿន ជាអភិបាលរងទី ១ ខេត្តសៀមរាប ។

**មាត្រា ២ .-** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ,ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ១៨២ អនក្រ.តត
## ស្ដីពីការជូនមេដាយការងារ

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ

### សំរេច

មាត្រា ១ ._ ត្រូវបានប្រគល់មេដាយការងារ ថ្នាក់លេខ១ ថ្នាក់លេខ ២ ថ្នាក់លេខ ៣ ក្នុងម្នាក់ៗ ជូនថ្នាក់ដឹកនាំកងទ័ព និងនាយទាហាន ចំណុះអគ្គបញ្ជាការដ្ឋាន កងយោធពលខេមរភូមិន្ទ ចំនួន ២៥ រូប ដូចមានរាយនាម ខាងក្រោម៖

| | | | |
|---|---|---|---|
| ១ | -នាយឧត្តមសេនីយ៍ | កែ គឹមយ៉ាន | អគ្គមេបញ្ជាការ |
| ២ | -ឧត្តមសេនីយ៍ឯក | ម៉ុល សារឿន | អគ្គមេបញ្ជាការរង និងជានាយសេនាធិការចំរុះ |
| ៣ | -ឧត្តមសេនីយ៍ឯក | គន់ គីម | អគ្គមេបញ្ជាការរង |
| ៤ | -ឧត្តមសេនីយ៍ឯក | មាស សុផា | អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងទ័ពជើងគោក |
| ៥ | -ឧត្តមសេនីយ៍ឯក | ខាន់ សាវឿន | អគ្គមេបញ្ជាការរង |
| ៦ | -ឧត្តមសេនីយ៍ឯក | គួច ស៊ីផាន | នាយរងសេនាធិការចំរុះ |
| ៧ | -ឧត្តមសេនីយ៍ឯក | មល់ រឿប | នាយរងសេនាធិការចំរុះ និងជានាយក នាយកដ្ឋានស្រាវជ្រាវ ចារកិច្ច |
| ៨ | -ឧត្តមសេនីយ៍ឯក | ជា តារា | នាយរងសេនាធិការចំរុះ និងជានាយកទីចាត់ការ កលយុទ្ធ |
| ៩ | -ឧត្តមសេនីយ៍ឯក | ជុំ ឈាន | នាយរងសេនាធិការចំរុះ |
| ១០ | -ឧត្តមសេនីយ៍ឯក | ញឹក ហ៊ួន | នាយរងសេនាធិការចំរុះ |
| ១១ | -ឧត្តមសេនីយ៍ទោ | ហ៊ុន តឿន | នាយរងសេនាធិការចំរុះ |
| ១២ | -ឧត្តមសេនីយ៍ទោ | ឆូ ស៊ុន | នាយកខុទ្ទកាល័យ អគ្គមេបញ្ជាការ |

| | | | |
|---|---|---|---|
| ១៣ | -ឧត្តមសេនីយ៍ទោ | គីម ហង្ស | ទីប្រឹក្សា អគ្គមេបញ្ជាការ |
| ១៤ | -ឧត្តមសេនីយ៍ទោ | ប្រូចម៉ ម៉ុនថុល | ទីប្រឹក្សា អគ្គមេបញ្ជាការ |
| ១៥ | -ឧត្តមសេនីយ៍ទោ | ស៊ូ គីមស៊ុន | ទីប្រឹក្សា អគ្គមេបញ្ជាការ |
| ១៦ | -ឧត្តមសេនីយ៍ទោ | ភាន់ រ៉ាត់ | ទីប្រឹក្សា អគ្គមេបញ្ជាការ |
| ១៧ | -ឧត្តមសេនីយ៍ទោ | ស៊ិន ចាន់ | ទីប្រឹក្សា អគ្គមេបញ្ជាការ |
| ១៨ | -ឧត្តមសេនីយ៍ត្រី | សេង វ៉ាន់ធី | នាយករង ឧត្តកាល័យ អគ្គបញ្ជាការ |
| ១៩ | -ឧត្តមសេនីយ៍ត្រី | ថ្លាំ ជុំទីណា | នាយករង ឧត្តកាល័យ អគ្គបញ្ជាការ |
| ២០ | -ឧត្តមសេនីយ៍ត្រី | ហេង ចំរើន | នាយករង ឧត្តកាល័យ អគ្គបញ្ជាការ |
| ២១ | -ឧត្តមសេនីយ៍ត្រី | អែម ម៉ាឌី | នាយករង ឧត្តកាល័យ អគ្គបញ្ជាការ |
| ២២ | -ឧត្តមសេនីយ៍ត្រី | ម៉ុល និត្យ | នាយករង ឧត្តកាល័យ អគ្គបញ្ជាការ |
| ២៣ | -ឧត្តមសេនីត្រី | ប្រាក់ សេន | ទីប្រឹក្សា អគ្គមេបញ្ជាការ |
| ២៤ | -វរសេនីយ៍ឯក | អ៊ុច សំណាង | នាយការិយាល័យ បុគ្គលិក ឧត្តកាល័យ |
| ២៥ | -វរសេនីយ៍ឯក | ម៉ម សំ | លេខាផ្ទាល់ឯកឧត្តម ម៉ុល សារឿន |

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ,ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ១៨៣ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពត

**សំរេច**

មាត្រា ១ ._ ត្រូវបានប្រគល់ **មេដាយសិរីវឌ្ឍនៈស្ថាបនាជាតិ** ជូនសប្បុរសជនខ្មែរ ០៨ រូប រស់នៅសហរដ្ឋអាមេរិកដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសាលាបឋមសិក្សាប្រភ្នំ ក្នុងឃុំប្រភ្នំ ស្រុកអង្គរជ័យខេត្តកំពត ដូចមានរាយនាម និងចំនួនទឹកប្រាក់អំណោយខាងក្រោមនេះ ៖

| | | | |
|---|---|---|---|
| ១ | -លោក អ៊ុក សុខុម | និងភរិយា | ទឹកប្រាក់ ៣.០០០ USD |
| ២ | -លោក ភាន់ តែម | និងភរិយា | ទឹកប្រាក់ ៣.០០០ USD |
| ៣ | -លោក អ៊ូច សាវណ្ណ | និងភរិយា | ទឹកប្រាក់ ៣.០០០ USD |
| ៤ | -លោកស្រី មន្ថា ម៉ិត | និងស្វាមី | ទឹកប្រាក់ ៣.០០០ USD |
| ៥ | លោកស្រី ឈៀង ណាច | និងស្វាមី | ទឹកប្រាក់ ៣.០០០ USD |
| ៦ | -លោកយាយ ម៉ូ ណាន់ | | ទឹកប្រាក់ ៣.០០០ USD |
| ៧ | -លោក អាត់ ហ៊ល | និងភរិយា | ទឹកប្រាក់ ៣.០០០ USD |
| ៨ | -លោកស្រី សាន់ វេញហ្គិច | | ទឹកប្រាក់ ៣.០០០ USD |

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១៨៤ អនក្រ.តត

## ស្តីពីការជូនមេដាយមាស ស្ថាបនាជាតិ

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេច **ហេង សំរិន**

**សំរេច**

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនឯកឧត្តម **មាស សុត្ថា** ទីប្រឹក្សាសម្តេច **ហេង សំរិន** អនុប្រធានទី១ រដ្ឋសភាជាតិ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយដាក់លូទឹក និងកសាងផ្លូវលំមួយខ្សែ នៅសង្កាត់ស្ទឹងមានជ័យ ក្នុងខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ចំណាយអស់ទឹកប្រាក់ចំនួន ៦៣.៥៩២ ដុល្លារអាមេរិក ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុករាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយបានទទួលលទ្ធផលល្អ ។

រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

## អនុក្រឹត្យលេខ ១៨៥ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តតាកែវ

**សំរេច**

មាត្រា ១ ._ ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនសមាគម Sotoshu Fukusen Ji Temple International Volunteer Association ( SFIVA ) ដែលបានជួយសាងសង់អាគារសិក្សាមួយខ្នងមាន ០៥ បន្ទប់ ដោយមានបំពាក់សម្ភារៈសិក្សាគ្រប់គ្រាន់ រួមទាំងបង្គន់អនាម័យមួយខ្នង ជូនសាលាបឋមសិក្សា ត្រាំ ក្នុងឃុំរការព្រៅ ស្រុកដូនកែវ ខេត្តតាកែវ ចំណាយអស់ទឹកប្រាក់ចំនួន ២១.៦៩៩,២៨ ដុល្លារអាមេរិក ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡានិងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ១៨៦ អនក្រ.តត

### ស្តីពីការជូនមេដាយ ស្ថាបនាជាតិ

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
